# ដំណាំដំឡូងជ្វា (Sweet Potato)

ឈ្មោះគ្រួសារ : Convulvoaceac

ឈ្មោះវិទ្យាសាស្ត្រ : Impomea Batatas

ឈ្មោះអង់គ្លេស : Sweet Potato

ឈ្មោះបារាំង : Patate Douce

I – រដូវ កាលដាំដុះទីកន្លែង និងការរៀបចំដី :

**១ រដូវកាលដាំដុះ :** ពេញមួយឆ្នាំ ដាំដុះបានគ្រប់រដូវ ។

- រដូវវស្សា : ចាប់ដាំនៅខែ ឧសភា ( ដើមរដូវវស្សា)
- រដូវប្រាំង : ចាប់ដាំនៅខែ វិច្ឆិកា ( ចុងរដូវវស្សា)
- ប្រមូលផល : ១០០ ថ្ងៃ ទៅ ១៨០ ថ្ងៃ ក្រោយពេលដាំ ។

**២ ទីកន្លែង :**

- ដីមានជីជាតិ ធូរ ជ្រាបទឹកបានល្អ ជាដីទួលល្បាយខ្សាច់មានជីជាតិល្អ ។
- ដីល្បាយខ្សាច់, ដីល្បាប់, ដីខ្មៅ, និង ក្រហមស្រទាប់លើធូរដាំមិនរើសដី ។
- ដីឥដ្ឋការលូតលាស់ដើមបានល្អ ប៉ុន្តែការលូតលាស់មើមមិនសូវល្អទេ ។
- PH = 5.6 – 6.6

**៣ ការរៀបចំដី :**

- កាប់, ភ្ជួររាស់ ៣ ដង
- កាប់ ភ្ជួររាស់លើកទី ១ ជំរៅ ៣០ ស .ម ហាលចោល ១០ ទៅ ១៥ ថ្ងៃ អោយដីស្ងួតល្អ ហើយកាប់, ភ្ជួររាស់ជាលើក ទី ២ រួចរាស់បំបែកដីអោយម៉ត់កៀរអោយស្មើ ។

II - ការដាំដុះ :

**១ ការលើករង :**

- រដូវប្រាំង លើករងកំពស់ ២០ ស,ម បណ្តោយ ១០ ម និង ទទឹង ១ ម លើកតែមសងខាងខ្ពស់ហើយផតកណ្តាល ។
- រដូវវស្សា លើករងកំពស់ ២៥ ទៅ ៣០ ស,ម បណ្តោយ ១០ ម ទទឹង ១ ម លើកក្រពង់កណ្តាលរាងខ្នងអណ្តើក ។

## ២ ការរៀបចំពូជសំរាប់ដាំ និងការទុកពូជ :

ក្រោយពីប្រមូលផលហើយយើងកាត់ទងទៅផ្សាំក្រោមម្លប់ឈើ ដាក់ជី អោយច្រើនដើម្បីអោយដើមមានការលូតលាស់ខ្លាំង កុំអោយត្រូវក្តៅខ្លាំងពេកដើម្បីរក្សាដើមអោយនៅខ្ចីបានយូរ ព្រោះកាលណាដើមចាស់មើមមិនធំទេ ។ ការដាំដុះមាន លក្ខណះច្រើនយ៉ាងគឺ :

ក ដាំដោយគ្រាប់ : សំរាប់ដាំពូជថ្មី

ខ ដាំដោយមើម : សំរាប់បណ្តុះដាំ នៅរដូវក្រោយ ។

គ ដាំដោយទង( ដើម) : យើងកាត់ទងដំឡូងជ្វាប្រវែង ៣០ ទៅ ៤០ ស,ម ដែលមាន៥ ទៅ ៦ ថ្នាំងរួចយកទៅដាំដោយកប់ក្នុងដី ទុកតែផ្នែកខាងលើមួយថ្នាំងបានហើយ បើទុកវែងពេកការលូតលាស់មានស្លឹកច្រើនធ្វើអោយដំឡូងពុំសូវមានមើម ។

## ៣ ការដាំដុះ :

- យកទងដំឡូងជ្វាមាន ៥ ទៅ ៦ ថ្នាំង ទៅកប់ក្នុងដី ទុកផ្នែកខាងលើតែមួយថ្នាំងបានហើយ បើទុកវែង នាំអោយលាស់ស្លឹកច្រើនតែមើមតិច ។
- ដាក់ចន្លោះជួរ ៣០ ស,ម និង ចន្លោះគុម្ព ៣០ ស,ម ដាំលើរង ទទឹង ១ ម បណ្តោយ ១០ ម ។

## ៤ ការដាក់ជី :

## ក ជីទ្រាប់បាត :

- ជីកំប៉ុស្ត ឬ លាមកសត្វ ០,៨ គីឡូក្រាម ក្នុង ១ ម៉ែត្រការ៉េ ដែលស្មើនិង ៨ តោន ក្នុង ១ ហិកតា ។
- ជី 15-15-15 ចំនួន ០,០២ គីឡូក្រាម ក្នុង ១ ម៉ែត្រការ៉េ ដែលស្មើនិង ២០០គីឡូក្រាម ក្នុង ១ ហិកតា ។

## ខ ជីបំប៉នពេលចាប់ផ្តើមមើម :

- ប្រើជី 15-15-15 ចំនួន ០,០២ គីឡូក្រាម ក្នុង ១ ម៉ែត្រការ៉េ ដែលស្មើ និង ២០០ គីឡូក្រាម ក្នុង ១ ហិកតា ។

III- ការថែទាំ

## ១ - ការស្រោចទឹក :

មិនចាំបាច់ស្រោចទឹកទេ នាំអោយដីក្តាំងហើយរិតតែនាំអោយឆាប់ស្ងួតថែមទៀត ។

**២ - ការពូនគល់ :**

បើរាំងភ្លៀងហើយគួរតែកាប់ដីពូនរងអោយបានកំពស់ ៣៥ ស.ម ដើម្បីរក្សាភាពសើមនៅក្នុងដីអោយបានយូរ ព្រោះដីម៉ត់ស្លួតល្អនៅលើរងអាចការពារមិនអោយជាតិទឹកហួតឡើងពីក្នុងដី ឬក្នុងរង ។

**៣ - ការគ្របរង :**

ដំឡូងជ្វាត្រូវការសំណើមខ្ពស់ ដូច្នេះយើងត្រូវការគ្របរងបើអាចធ្វើទៅបាន( ប្រើចំបើងខ្ចី)ការពារសំណើម កុំអោយជាតិទឹកនៅស្រទាប់ដីក្រោមហួតអស់នាំអោយដំឡូងជ្វាគ្មានមើម ម្យ៉ាងទៀតត្រូវការពារដៃទងដំឡូងជ្វាកុំអោយវាប៉ះដី នាំអោយចាក់ឫសច្រើនថែមទៀតដែលធ្វើអោយមើមមិនបានធំល្អ ។

**៤ - ការក្តិចត្រួយ និងទងចេញ :**

ត្រូវឧស្សាហ៍ក្តិចត្រួយចេញដើម្បីអោយមើមវាធំដោយទុកប្រវែងមិនអោយលើសពី ២ម៉ែត្រ បើទុកខ្នែងច្រើននាំអោយមើមតូចតែបើទងតិចពេក ក៏នាំអោយមើមមិនធំល្អដែរ ។

**៥ - ជំងឺ :**

ផ្សិត Black rot, ផ្សិត Fusarium ជាជំងឺដែលដំឡូងជ្វាមិនសូវរងគ្រោះធ្ងន់ធ្ងរទេ ។

**៦ សត្វល្អិតចង្រៃ :**

ដូចខ្លួតពណ៌ខ្មៅ ឬ សត្វគីង Cylas Fermicarus ការការពារប្រើ : Sex Pheromone សំរាប់ទាក់ទាញសត្វគីងឈ្មោលអោយធ្លាក់ទឹកងាប់ ។

- ដាំផ្លាស់មុខដំណាំ : ដាំ ១ ឆ្នាំ ផ្លាស់មុខដំណាំផ្សេង ១គ្នា
- កុំដាំដំឡូងជ្វានៅក្បែរចំការ ឬ នៅក្នុងចំការដែលមានសត្វគីងបំផ្លាញពីរដូវមុនមក
- ជ្រើសរើសទងល្អគ្មានការបំផ្លាញពីសត្វគីង
- លុបដីដែលប្រេះក្រហែងចោល ។

IV - ការប្រមូលផល :

- ការប្រមូលផលពី ១០០ ទៅ ១៨០ ថ្ងៃ ក្រោយពីពេលដាំ
- ពេលជិតគាស់ត្រូវឧស្សាហ៍ ឆ្កឹសឫស គល់មើមថាតើមានសត្វគីងស៊ីទេ បើមិនមានទេយើងអាចពន្យាពេលគាស់ បាន ។ នៅរដូវប្រាំងកាលណាទុកយូរពេកនាំអោយសត្វគីងស៊ី ឬ ដុះពន្លកពីមើម ។
- គាស់ដោយប្រើចប ឬ ចបជីក ឬភ្ជួររើសមើម

- អាចប្រមូលផលពី ៣០ ទៅ ៣៥ តោន ក្នុងមួយហិកតា ។

# ដំណាំដំឡូងមី (Cassava)

ឈ្មោះគ្រួសារ : Euphorbiaceac

ឈ្មោះវិទ្យាសាស្រ្ត : Manihot Esculenta

ឈ្មោះអង់គ្លេស : Cassava

ឈ្មោះបារាំង : Manioc

## I - រដូវកាលដាំដុះ ទីកន្លែង និង ការរៀបចំដី

### ១.រដូវកាលដាំដុះ

- ពេញ ១ឆ្នាំ អាចដាំបានគ្រប់រដូវ
- រដូវវស្សា កក្កដា- សីហា ,ដើមរដូវប្រាំង វិច្ឆិកា- ធ្នូ ។
- ការប្រមូលផលចាប់ពី ១៥០-១៨០ថ្ងៃក្រោយពេលដាំ ( ពូជធ្ងន់ការប្រមូលផលអាចរហូតដល់១ឆ្នាំ)

### ២.ទីកន្លែងដាំដុះ

- ដីទួលមានជីជាតិ ហើយដីធូរ និង ដីស្រស់ទឹក ( ដីមិនដក់ទឹក)
- ដីល្បាប់ ល្បាយខ្សាច់ ដីខ្មៅ និង ដីក្រហមមានស្រទាប់លើធូរ
- ដាំមិនរើសប្រភេទដី ដែលមាន pH=៥.៥ - ៨

### ៣- ការរៀបចំដី :

- កាប់ ឬ ភ្ជួរ រាស់ ៣ដង
- កាប់ ឬ ភ្ជួរ រាស់លើកទី១ ជំរៅ ២៥-៣០ សម ហាលដីចោលពី ១០ទៅ ១៥ ថ្ងៃ ហើយកាប់ ភ្ជួរលើកទី ២ រាស់បំបែកដីអោយមត់ គៀរអោយស្មើ ហើយកាប់ ឬ ភ្ជួរជាលើកទី ៣។

## II- ការដាំដុះ

### ១ ,ការលើករង

-រដូវប្រាំងលើករងកំពស់ ២០ សម បណ្តោយ ១០ម ទទឹង ១ម ឬក៏ទៅ តាមផ្ទៃដី

-រដូវវស្សាលើករងកំពស់២៥-៣០សមបណ្តោយ១០មទទឹង ១មលើកក្រពង់កណ្តាលរាងខ្នង អណ្តើក។

**២ ,ការរៀបចំពូជសំរាបដាំ នឹង សំរាប់ទុកពូជ :**

ក្រោយពីគាស់យកមើមរួច កាប់ដើមទៅផ្សាំ ទុកពូជ ឬ ដើមសំរាប់ធ្វើពូជត្រូវមាន លក្ខណៈដូចតទៅ:

- ពូជ ឬ ដើមធំ និងមានមេ្បាច្រើនមានទិន្នផលខ្ពស់
- មានជាតិប្រូតេអ៊ីនច្រើន
- មានជាតិអាស៊ីតស្យានី ឬ ជាតិពុលតិច
- រយៈពេលដុះ និង លូតលាស់ខ្លី

**៣ ,ការដាំដុះ :**

- ដាំដោយលើករង ឬក៏ ដាំផ្ទាល់ ហើយយើងអាចដាំតាមបៀបដូចជា:ដាំផ្តេកវីដាំ បញ្ឈរ ដាំបញ្ឆិត។

-កាត់ដើមដំឡូងណាដែលចាស់ល្អ នៅស្រស់ៗប្រវែង ២០-៤០សម មាន ភ្នែកពី ៤-៦ គេអាចដាំតាម ២ របៀប :

**ក.ដាំលើករង** : កាប់រណ្តៅតូចល្មមលើរងរួចយកដើមដែលកាត់ខ្លីៗទៅកប់ក្នុងរណ្តៅរាងផ្តេកឬបញ្ឈរ ឬ បញ្ឆិត ។ គេច្រើនដាំលើករងនៅរដូវវស្សា ។

**ខ ,ការដាំផ្ទាល់** : កាប់រណ្តៅទំហំ ០,៥ម ដាក់ជីកំប៉ុស្តិ ឬ លាមកសត្វច្របល់ឱ្យសព្វនៅបាតរណ្តៅ រួចយកដើមដែលកាត់ខ្លីៗទៅកប់ក្នុងរណ្តៅរាងផ្តេកហើយបញ្ឈរ ឬ បញ្ឆិត ចំពោះការដាំផ្ទាល់ច្រើនធ្វើនៅរដូវប្រាំង ។

**៤ ,ការដាក់ជី :**

**ក -** ដាក់ជីទ្រាប់បាត :

-ជីលមកសត្វ ឬ ជីកំប៉ុស្ត០,៨ Kg/m$^2$=8t/ha

- ជី ១៥-១៥-១៥= ០,០២ Kg/m$^2$=200Kg/ha

ខ- ការដាក់ជីបំប៉នពេលចាប់ផ្តើមមើម :

- ជី ១៥-១៥-១៥=0,02Kg/m2=200Kg/ha

**៥,ការថែទាំ:**

ក - ការស្រោចទឹក : ស្រោចទឹកក្រោយពេលដាំរួចភ្លាម

ខ - បោចស្មៅ ជ្រួយដី ពូនគល់

- ត្រូវបោចស្មៅឱ្យបានញឹកញាប់ពេលដំឡូងមីនៅតូច

- រយៈពេល ២-៣ ខែ ក្រោយពេលដាំទូវពូនគល់ ដើម្បីទប់ដើមកុំឱ្យរលំដួល ហើយមើមធំល្អ។

គ- ការលួតលាស់:

- នៅពេលដើមដំឡូងមីមានកំពស់ពី ៨០-១០០សម គេអាលួសស្លឹកខាងក្រោយចេញ ដើម្បីឱ្យមើម វាធំបានល្អ។

**៦, ជំងឺ :**

-Mosaic Virus ការការពារគឺដកដើមដែលមានជំងឺចេញឬក៏ប្រើពូជធន់និងជំងឺ ( បាញ់ថ្នាំសំ លាប់ សត្វល្អិត ដែលជាភ្នាក់ងារចំលងជំងឺ) ។

**៧, សត្វ និង សត្វល្អិតចង្រៃបំផ្លាញ :**

- ប្រភេទសត្វធំៗ ដូចជា ជ្រូក ឈ្លូសស៊ីមើម,គោស៊ីស្លឹក

- សត្វល្អិតចង្រៃបំផ្លាញមានពីងពាងក្រហម

III - ការប្រមូលផល:

**១ ការប្រមូលផល :**

-សំរាប់ធ្វើម្ហូបអាហារយើងអាចប្រមូល ១៥០-១៨០ ថ្ងៃក្រោយពេលដាំ ។ ចំពោះពូជស្រាល ( ចំពោះ ពូជធ្ងន់ ១ឆ្នាំ) ។ យើងអាចសំគាល់បានដោយស្លឹកមានពណ៌លឿងដែលនៅក្បែរគល់ចាប់ផ្តើមជ្រុះដេញពីក្រោម ទៅលើ។ មុនគាស់ប្រមូលផលត្រូវកាប់ដើមចេញ ដោយទុកប្រវែង៣០-៤០សមពីដី ។

**២ , ការទុកដើមធ្វើពូជ :**

ក្រោយពីកាត់ដើមយកមើមរួចយើងកាត់ដើមយកទៅផ្សាំហើយពូជសំរាប់ដាំត្រូវមានលក្ខណៈដូចតទៅ

- ពូជ ឬ ដើមធំរឹងមាំល្អ ហើយធន់និងជំងឺ ជាពិសេសជំងឺវីរុស

- មានកំរិតម្សៅច្រើនគឺ មានទិនផលខ្ពស់

- មានជាតិប្រូតេអ៊ីនច្រើន

- មានជាតិអាស៊ីតស្យានីទ្រិក ឬ មានជាតិពុលតិច

- រយៈពេលដាំដុះហើយលូតលាស់ខ្លី

****

# ដំណាំល្ហុង (Papaya)

ដំណាំល្ហុងក៏ជាដំណាំឈើហូបផ្លែដែរដែលមានសារៈប្រយោជន៍ ចំពោះមនុស្ស និងសត្វ ។ វាជាប្រភពមួយផ្តល់នូវជីវជាតិផ្សេងៗ ដូចជាអង្គធាតុរ៉ែ, សារធាតុសរីរាង្គ, ដែលចាំបាច់សំរាប់មនុស្ស ហើយមាន វីតាមីនអា និងវីតាមីនសេ ។ បរិភោគផ្លែល្ហុងទុំជួយក្នុងការរំលាយអាហារ ។ ក្រៅពីនេះផ្លែខ្ចីគេអាចយកទៅធ្វើជាបន្លែសំរាប់ស្ងោរ ជ្រក់ ។ល។

នៅប្រទេសកម្ពុជាយើងដំណាំល្ហុងត្រូវបានប្រជាជនដាំដុះតាំងពីយូរយាណាស់មកហើយ ។ តំបន់ដែលសំបូរដំណាំល្ហុងជាងគេគឺតំបន់ទំនាបកណ្តាលទន្លេមេគង្គដូចជា ខេត្តកណ្តាល, កំពង់ចាម, កំពង់ឆ្នាំងជាដើមពិសេសប្រជាជនដាំជាលក្ខណៈ គ្រួសារនៅជុំវិញផ្ទះ និងជាដំណាំយថាផល ។ ការដាំដំណាំនេះគឺមានបំណងគ្រាន់ធ្វើជាបន្លែផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃនិង សល់ពីការហូបចុកខ្លះសំរាប់យកទៅលក់នៅទីផ្សារតែប៉ុណ្ណោះ ។

ល្ហុងមានឈ្មោះវិទ្យាសាស្ត្រថា : Carica papaya ដែលស្ថិតក្នុងសណ្តាន Caricaceae ។ ឈ្មោះជាភាសាអង់គ្លេស Papaya, Paw Paw ។

I - អំពីពូជ :

បណ្តាពូជល្ហុងនៅអាមេរិកខាងត្បូង, ខាងជើង និង អាមេរិកកណ្តាលមានជាង ៣០ ប្រភេទដោយនៅប្រទេសកម្ពុជាយើងពូជល្ហុងដែលគេតែងតែជួបប្រទះមាន :

- **ពូជល្ហុងល័ក្ខ**: ពូជប្រភេទនេះត្រូវបានប្រជាជននិយមចូលចិត្តដាំជាងគេដោយសារវាមានឱជារស់ឆ្ងាញ់ពិសារ ។ ពូជប្រភេទនេះមានដើមពណ៌ស្វាយបន្តរហូតដល់ធាង និងស្លឹក ។ ផ្លែខ្ចីមានពណ៌បៃតងខ្ចីរាងទ្រវែងនិងមានគ្រាប់តិច។ ផ្លែទុំមានសំបកពណ៌លឿង និងសាច់ពណ៌ក្រហម។
- **ពូជល្ហុងដំឡូង :** ពូជប្រភេទនេះពុំសូវបានប្រជាជននិយមចូលចិត្តដាំទេ ព្រោះវាពុំសូវមានឱជារស ។ ពូជប្រភេទនេះមានដើម និងផ្លែពណ៌បៃតង ផ្លែទុំពណ៌លឿងពុំសូវផ្អែម គ្រាប់ច្រើន តែងាយស្រួលក្នុងការដាំដុះ ។

ក្រៅពីនេះនៅមានពូជជាច្រើនទៀតដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាទាំងដើម ទាំងផ្លែ ។ ដំណាំល្ហុងអាចដុះលូតលាស់និងផ្តល់ផ្លែបានក្នុងរយៈពេល ២០ឆ្នាំ ឬច្រើនជាងនេះ ។ ប៉ុន្តែវាផ្តល់ទិន្នផលខ្ពស់តែក្នុងរយៈពេលពី ៣ទៅ ៤ ឆ្នាំប៉ុណ្ណោះ ។ ក្រោយមកទិន្នផលត្រូវថយចុះជាលំដាប់ ឯគុណភាពផ្លែក៏អន់ថយដែរ ។

II . ការកំណត់ភេទល្ហុង :

ការកំណត់ប្រភេទល្ហុង គឺមានវិធីផ្សេងៗគ្នាអាស្រ័យទៅតាមការនិយមរបស់ប្រទេសខ្លះ ។ ដើម្បីកំណត់ភេទល្ហុងគេយកស្លឹកនៃដើមណាមួយមកកិន ហើយច្របាច់កទឹកនោះលាយជាមួយទឹកបារត ។ បើសិនទឹកលាយនោះប្រែពណ៌ទៅជាបៃតងគេកំនត់ថាដើមនោះជាដើមញីតែការកំណត់នេះគឺមានប្រសិទ្ធភាពតែត្រឹម ៨៧ % តែប៉ុណ្ណោះ។ ដោយឡែកនៅប្រទេសកម្ពុជាយើងប្រជាជនកំណត់ភេទល្ហុងតាមលក្ខណៈរូបសាស្ត្របើកូនល្ហុងណាមានការលូតលាស់ខ្លាំងជាងគេនៅក្នុងថ្នាលគេសន្មតថាជាដើមឈ្មោលឬមានវិធីម្យ៉ាងទៀតគឺគាស់កូនល្ហុងដើម្បីពិនិត្យមើលឬសបើសិនជាឃើញឬសកែវបែកជាពីរគេសន្មតថាជាល្ហុងញីប៉ុន្តែវិធីនេះពុំមានប្រសិទ្ធិភាព ១០០% ទេ ។

III- លក្ខខណ្ឌដី និងអាកាសធាតុសមស្រប :

## ១. របបទឹកភ្លៀង:

របបទឹកភ្លៀងដែលដំណាំល្ហុងត្រូវការ គឺអាចកើនឡើងរហូតដល់១៥០០ម.ម ក្នុងមួយឆ្នាំ ។ លក្ខណ្ឌតំបន់ត្រូពិចល្អប្រសើរសំរាប់ការលូតលាស់របស់ល្ហុង បើសិនជាមិនសូវមានភ្លៀងខ្លាំង និងមានពពកច្រើន ។ កំរិតទឹកភ្លៀងដែលតិចបំផុតសំរាប់ដំណាំល្ហុង គឺ១០០ម.ម ក្នុងមួយឆ្នាំបើតិចជាងនេះល្ហុងមិនអាចរស់បានឡើយ ។

## ២. សីតុណ្ហភាព:

ដំណាំល្ហុងអាចដុះបាននៅក្នុងតំបន់ដែលមានសីណ្ហភាពមធ្យម។ សីតុណ្ហភាពសមស្របសំរាប់ដំណាំល្ហុងគឺពី ២២ ទៅ ២៨ អង្សាសេ ហើយវាក៏អាចដុះលូតលាស់បានដែរនៅតំបន់ដែលមានសីតុណ្ហភាព ១៨ អង្សាសេ ។ សីតុណ្ហភាពនេះមានឥទ្ធិពលសំខាន់ណាស់សំរាប់ការលូតលាស់របស់ដំណាំល្ហុង។ ដំណាំនេះមានការលូតលាស់លឿននៅរដូវវស្សា រីឯរដូវប្រាំងទោះជាមានការស្រោចស្រពក៏ដោយក៏ការលូតលាស់ពុំសូវល្អដែរ ។ ព្រោះនៅរដូវប្រាំងសីតុណ្ហភាពមានកំរិតខ្ពស់ពេក ។

## ៣. ដី:

ដំណាំល្ហុងត្រូវការដីមានសភាពធូររជ្រៅហើយស្រោះទឹក និង សំបូរជីជាតិ ជាពិសេសគឺដីកណ្តុង ឬដីខ្សាច់ល្បាយដីបាសាល ។ ការពិសោធន៍បានបញ្ជាក់ថា ប្រភេទដីល្បាយខ្សាច់មានលក្ខណៈពិសេសដូចតទៅ :

- កំរិតបរិមាណដីដែលហូរច្រោះចេញពីគល់ល្ហុងមានចំនួនតិចតួចមិនប៉ះពាល់ដល់ប្រព័ន្ធឬសនិងមិនងាយធ្វើអោយដើមរលំដួល ។
- មិនបៀមទឹកដែលអាចជៀសវាងបាននូវជម្ងឺរលួយឬសកើតឡើងនៅក្នុងរដូវភ្លៀងធ្លាក់ខ្លាំង ។

- នៅរដូវប្រាំងអាចរក្សាសំណើមបានយូរជាងដីខ្សាច់ ។ ដំណាំល្ហុងត្រូវការដីដែលមានប្រភពទឹកក្រោមដីជ្រៅបន្តិច ឬជាតិសើមជំរៅយ៉ាងតិច ២ម៉ែត្រ ។ នៅតំបន់ណាដែលមានភ្លៀងធ្លាក់ខ្លាំងគេដាំល្ហុងនៅលើដីទួល ឬដីជំរាលដើម្បីជៀសវាងការដក់ទឹក ។ ដំណាំល្ហុងពុំត្រូវការដីដែលមានជីជាតិជូរពេកទេ ( pH ប្រហែលពី៦.៥ ទៅ ៧) និងសំបូរទៅដោយជាតិ N,P,K,Fe,Cu ជាដើម។ ដីដែលមាន pH ក្រោម ៥.០ ត្រូវបាចកំបោរដើម្បីកាត់បន្ថយជំងឺរលួយគល់ ។ ដំណាំល្ហុងដែលគេនិយមដាំណៅប្រទេសកម្ពុជាមានពីរកន្លែង គឺនៅតំបន់ខ្ពង់រាប និងតំបន់តំនាបកណ្តាល ។

IV - វិធីសាស្ត្រក្នុងការដាំដុះ :

## ១- ការជ្រើសរើសទីកន្លែងដាំដុះ :

គេអាចដាំល្ហុងបាននៅលើដីច្រើនប្រភេទលើកលែងតែដីលិចទឹក ។ ដំណាំល្ហុងជារុក្ខជាតិដែលអាចចាក់ឫសភាគច្រើននៅដីស្រទាប់លើគួបផ្សំនឹងដើមឆាប់បាក់ និងរលំដួលដោយសារខ្យល់ដូច្នេះចំការល្ហុងត្រូវជ្រើសរើសទីកន្លែងណាដែលមានរុក្ខជាតិធំៗល្មម ដើម្បីជារបាំងខ្យល់និងការពារកំដៅថ្ងៃ ។

## ២- របៀបដាំដុះ :

- ការរៀបចំថ្នាលបណ្តុះកូន : ជាដំបូងគេត្រូវកាប់ដីលើកជាថ្នាលតូចមួយដែលមានទទឹង ១ម៉ែត្រ និងបណ្តោយ២ម៉ែត្រដោយសំអាតស្មៅអោយអស់ធ្វើដីអោយម៉ត់ល្អធ្វើដំបូលអោយមានជាម្លប់ខ្លះៗ ដើម្បីអោយមានបន្ទីព្រះអាទិត្យអាចចាំងចូលបាន ។

-ការជ្រើសរើសពូជ : យើងត្រូវជ្រើសរើសផ្លែល្ហុងទុំមួយ ដើម្បីយកគ្រាប់សំរាប់ធ្វើពូជា ។ គេរតូវយកគ្រាប់ទៅ សាបក្នុងថ្នាលដែលបានធ្វើរួចដោយកប់ដីជំរៅ៥ម.ម ។

-ការថែរទាំកូន : ក្រោយពេលកូនល្ហុងដុះបានកំពស់ល្មមគេគាស់វាដាក់ក្នុងថង់ប្លាស្ទិច ។ នៅពេលកូនល្ហុងមានអាយុប្រហែល ១ ខែកន្លះ ទៅ២ខែ គេយកវាទៅដាំនៅក្នុងចំការតែម្តងដោយ ដាំក្នុងមួយរណ្តៅ២ទៅ ៣ដើម ។ មានវិធីម្យ៉ាងទៀតគេអាចសាបផ្ទាល់នៅ ក្នុងចំការតែម្តងដោយដាំក្នុងមួយរណ្តៅពី ៤ទៅ៥គ្រាប់ ។ នៅពេលដែលដើមល្ហុងចាប់ផ្តើមចេញផ្កា គេអាចកំណត់បានច្បាស់ថាជាដើមឈ្មោល ឬញី ។ ពេលនោះគេត្រូវកាប់ដើមឈ្មោលចោលទាំងអស់ទុកតែដើមញីទេ ។ ប៉ុន្តែក្នុងចំណោមដើមញីពី ២៥ ទៅ ១០០ដើម គេអាចទុកដើមឈ្មោលមួយដើមដើម្បីទុកលំអងបង្កាត់ ។

## ៣- ការធ្វើជីដាំ :

មុនពេលដាំគេត្រូវភ្ជួរដីអោយបានពី២ទៅ៣សារ ហើយកាប់រណ្តៅទំហំ០,៧ម៉ែត្រ ជំរៅ ០,៥ម៉ែត្រ ដោយដាក់លាកមគោពី ១០ ទៅ ២០គីឡូក្រាម ក្នុង១រណ្តៅ និង ចន្លោះពីគុម្ព១ទៅគុម្ព ១ ទៀត ២ម៉ែត្រ និង ចន្លោះពីរង១ ទៅរង១ ទៀតប្រវែង ២ ម៉ែត្រដែរ ។ ជីសរីរាង្គមានសារៈសំខាន់ណាស់ក្នុងការដាំល្ហុង ក៏ដូចដំណាំដ៏ ទៃទៀតដែរ ដោយដាក់តាំងពីពេលដាំម្លេះ ។ ចំណែកជីគីមីគេច្រើនប្រើនៅពេលកូនល្ហុងធំ រីពេលល្ហុងជិតអោយ ផល ។ ជាទូទៅគេចាប់ផ្តើមសាបគ្រាប់នៅពាក់កណ្តាលខែធ្នូហើយ ចាប់ផ្តើមដាំនៅខែកុម្ភៈ ។

V. ការការពារសត្វល្អិតចង្រៃ និងជម្ងឺ :

**- ណេម៉ាតូដ** : ធ្វើអោយល្ហុងរលួយគល់ ជាពិសេសដីដែលឆាប់ជាំទឹក ។ ត្រូវបាញថ្នាំពុលសំរាប់សំលាប់ណេម៉ាតូដ ។

**- ដង្កូវរុយចោះផ្លែ** : ដូចគ្នានឹងដង្កូវចោះផ្លែស្វាយដែរវាបំផ្លាញផ្លែល្ហុងដែលទុំ ។ យកល្អយើងត្រូវបេះផ្លែល្ហុងពេលទុំស្រគាលជៀសវាងការទុំនៅលើដើម ។

**- ពួកចៃជញ្ជក់ :** ច្រើនកើតនៅលើស្លឹកនិងក្តិបផ្លែ ។ ប្រើថ្នាំត្រៃបុង ,ម៉ាឡាចុង ។

VI . ការប្រមូលផល :

ក្នុងរយៈពេល១៨ ខែល្ហុងនឹងមានផ្លែ ។ ផ្លែទុំកាលបើវាប្រែពណ៌ពីតៃងទៅលឿង ។ត្រូវទុកដាក់រក្សាផ្លែល្ហុងទុំដោយប្រុងប្រយ័ត្នព្រោះសាច់វាទន់ណាស់ ។ កាលណាសំបកវាមានស្នាមជាំនាំអោយពិបាកក្នុង ការលក់ដូរ។ ដូចនេះត្រូវទ្រាប់ចំបើងក្នុងការដឹកជញ្ជូន ។

យើងអាចសន្និដ្ឋានបានថាក្រៅពីដំណាំហូបផ្លែដ៏ទៃទៀត ល្ហុងគឺជាដំណាំហូបផ្លែម្យ៉ាងដែលមានលក្ខណៈងាយស្រួលក្នុងការដាំដុះមិនទាមទាថវិការច្រើនពេកទេគឺវាមានលក្ខណៈប្រសើរដែលប្រជាជនអាចមានលទ្ធភាពដាំបានយ៉ាងងាយនៅលើដីចំការរបស់គាត់ ។ ដំណាំល្ហុងនេះមិនសូវមានជំងឺដែលនាំអោយពិបាកក្នុងការថែទាំទេ តែវាជាដំណាំចាញ់ទឹកដូចនេះគប្បីដាំនៅលើដីណាដែលមិនលិចទឹកឬដក់ទឹក ។ ក្នុងការទ្រទ្រង់សុខភាពផ្លែល្ហុងទុំសំបូរទៅដោយវីតាមីនគ្រប់យ៉ាងសំរាប់សុខភាពជាពិសេសវាអាចជួយសំរួលដល់ការំលាយអាហាររបស់មនុស្ស ។

# ដំណាំស្វាយ (mongo)

ដំណាំស្វាយគឺជាប្រភេទដំណាំដែលមានអាយុកាលវែងជាងដំណាំឈើហូបផ្លែដ៏ទៃទៀតហើយវាផ្តល់ផល ១ ដងក្នុង ១ឆ្នាំទៅតាមរដូវកាលរបស់វា ។ ដំណាំស្វាយគឺជាប្រភេទដំណាំដែលមានសារៈសំខាន់ចំពោះ មនុស្ស និងសត្វ ។ វាផ្តល់នូវជីវជាតិផ្សេងៗដូចជា សារធាតុខនិជ សារធាតុសរីរាង្គដែលជាសារធាតុចាំបាច់សំរាប់មនុស្ស ក្នុងការបណ្តុះរូបធាតុ ។ ក្រៅពីនេះផ្លែស្វាយទុំអាចផ្តល់នូវប្រភេទស្ករមួយចំនួនក៏ដូចជា គ្លុយកូស សាក់ការ៉ូស និង វិតាមីន A,B,$B_6$,C,PP ។ល។

ដំណាំស្វាយឋិតក្នុងសណ្តាន Anacardiaceae មានឈ្មោះវិទ្យាសាស្ត្រថា Mangiferaindia។ ឈ្មោះជាភាសាបារាំង Arbre de mango,mangieur ។

នៅប្រទេសកម្ពុជាយើង ដំណាំស្វាមានពូជច្រើនប្លែកៗគ្នានៅតាមបណ្តាខេត្ត ហើយការដាំដុះទៀតក៏ ពុំឃើញមានលក្ខណៈជាចំការធំនៅឡើយ ។ ប្រជាជនច្រើនដាំតាមយថាផល និងជាលក្ខណៈគ្រួសារ ។

I – អំពីពូជ :

នៅលើពិភពលោក ពូជស្វាយមានច្រើនប្រភេទណាស់ដែលមានលក្ខណៈប្លែកៗគ្នាដូចជាដើមដង.ស្លឹក. ផ្កា និងផ្លែ ។ ឯការហៅឈ្មោះពូជនីមួយៗក៏មានការខុសគ្នាដែរ ។ ដោយឡែកនៅប្រទេសកម្ពុជាយើង គេសង្កេត ឃើញមានពូជស្វាយមួយចំនួនដែលប្រជាជនចូលចិត្តដាំ និងបរិភោគ :

- **ពូជកែវចិន** : ជាប្រភេទពូជដេលមានផ្លែរាងទ្រវែង សាច់ពណ៌លឿងព្រលែត មានសរសៃតិចតួច មានក្លិនក្រអូប ។ ពូជនេះគេនិយមបរិភោគ និងលក់បានតំលៃថ្លៃ ។ ពូជប្រភេទនេះចាប់ផ្តើមចេញផ្កានៅ ខែមករា និងទុំនៅ ខែមេសា ។
- **ពូជកែវសារី :** ជាពូជដែលមានផែរាងខ្លី កំប៉ោង មានសាច់ពណ៌លឿងព្រលែត និងមានសរសៃតិចតួច ចាប់ផ្តើមចេញផ្កាខែតុលា ហើយទុំនៅខែកុម្ភៈ ។
- **ពូជស្វាយក្បាលដំរី** : ផ្លែរាងមូលកន្តុល សាច់ជ្រាយ និងមានគ្រាប់ធំ ចេញផ្កានៅខែមករា ទុំនៅ មេសា ។

- **ពូជស្វាយពុំសែន** : ផ្លែរាងសំប៉ែត កន្ទុយផ្លែមានរាងកោងខុបបន្តិច សាច់ពណ៌ក្រហម រី លឿងនៅពេលទុំហើយចេញផ្កានៅខែមករា ទុំនៅខែមិនា និង ខែមេសា ។

II- ការបន្តពូជ :

ដំណាំស្វាយត្រូវបានគេដាំដោយគ្រាប់ ឬដោយមែកផ្សាំ ។ ការបន្តពូជដោយគ្រាប់គឺជាវិធីមួយដែលមានលក្ខណៈល្អជាងការដាំដោយមែកផ្សាំ។ ព្រោះការដាំដោយគ្រាប់ទើបរុក្ខជាតិដុះលូតលាស់បានល្អមិនសូវមានជំងឺធ្ងន់ធ្ងរនិងមជ្ឈដ្ឋានខាងក្រៅបង្កើតប្រព័ន្ធឫសដែលមានលក្ខណៈមាំល្អអាចស្រូបយកទឹក និងជីជាតិបានខ្លាំងពីក្នុងដី ។

កូនស្វាយដែលត្រូវយកមកដាំយ៉ាងហោចណាស់ក៏មានអាយុ៤សប្តាហ៍បន្ទាប់មករៀបចំដីក្នុងថ្នាលណ្តុះគ្រាប់ជាដំបូងត្រូវជ្រើសរើសកន្លែងសមស្របសំរាប់ធ្វើថ្នាលបណ្តុះបន្ទាប់មករៀបចំដីក្នុងថ្នាលបណ្តុះអោយម៉ត់ល្អដាក់ជីលាមកសត្វក្នុងកំរិត ៣០ តោនក្នុងមួយហិកតា ។ បន្ទាប់មកទៀតត្រូវជីករណ្តៅបណ្តុះដែលមានជំរៅពី ២.៥ ទៅ ៥ស.មនៅក្នុងលក្ខខណ្ឌដែលមានសំណើមគ្រប់គ្រាន់ ។ ម្យ៉ាងទៀតត្រូវបណ្តុះកូនស្វាយនៅលើដីខ្សាច់ ឬលើស្រកីដូងក្បែរពាងទឹក ។ ក្រោយពីដុះឫសយកវាទៅដាំបាន ។

III- ការជ្រើសរើសទីកន្លែងសំរាប់ដាំ :

ស្វាយជាដើមឈើហូបផ្លែមួយប្រភេទដែលមានអាយុកាលលូតលាស់វែង ជាងដំណាំហូបផ្លែដ៏ទៃទៀត ។ ដូចនេះការជ្រើសរើសទីកន្លែងសំរាប់ដាំដុះ ចាំបាច់ត្រូវគិតពីវិធានការណ៍ជារួម ដែលផ្តល់ប្រយោជន៍ដល់ការដាំដុះ និងការទទួលផល ។

ចំពោះការកំណត់ដីច្បារដំណាំជាការចាំបាច់ ។ ដូច្នេះត្រូវគិតពីកត្តាមួយចំនួនខាងក្រោមនេះ :

- ត្រូវជ្រើសរើសប្រភេទដីដែលសមស្របទៅតាមការទាមទាររបស់ដំណាំស្វាយ។ ដីត្រូវមាន pH ពី ៥.៥ ទៅ៧.៥។
- ជៀសវាងការដាំនៅលើដីដែលមានធាតុគីមីមួយចំនួនដែលផ្តល់លក្ខណៈពុំប្រសើរដល់ការលូតលាស់របស់វា ។
- ជ្រើសរើសដីដែលស្រោះទឹកល្អ ជៀសវាងការជាំទឹក ។
- ជ្រើសរើសទីកន្លែងមានទឹក . ខ្យល់.ពន្លឺ. និងសីតុណ្ហភាពសមស្រប ( ២៧ ទៅ ៣០អង្សាសេ) កំពស់ទឹកភ្លៀងប្រចាំឆ្នាំពី ៧៥០ ទៅ ២២៥០ម.ម សំណើមពី ៧០ ទៅ ៨០ ភាគរយ ។

IV. បច្ចេកទេសដាំដុះ :

ក្នុងការកំណត់ជួរឬចន្លោះជួរ និងដើមដែលត្រូវដាំ គឺគិតពីលក្ខអាកាសធាតុតាមតំបន់នីមួយៗ និងតាមប្រភេទពូជ ។ ប៉ុន្តែជាទូទៅត្រូវជីករណ្តៅដែលមានទំហំ០,៧ម៉ែត្រ ជំរៅ ០,៧ម៉ែត្រ ដោយដាក់ស្រទាប់ដីទី១ជំរៅ ០,៣ ម៉ែត្រនៅមួយកន្លែង និងស្រទាប់ទី២ចំរៅ ០,៤ ម៉ែត្រនៅមួយកន្លែង បន្ទាប់កមត្រូវដាក់ជីកំប៉ុស្តដែលពុកផុយល្អចូលទៅបាតរណ្តៅកំរាស់ ១០-២០សង់ទីម៉ែត្រ ហើយលុបដីស្រទាប់១ រួចដាក់ជីកំប៉ុស្តដែលពុកផុយល្អចូលទៅក្នុងរណ្តៅកំរាស់ ៥-១០សង់ទីម៉ែត្រ ហើយលុបដីស្រទាប់ ២កំរាស់២០សង់ទីម៉ែត្រ ។ ក្រោយមកដីដែលត្រូវយកទៅបំពេញរណ្តៅត្រូវលាយជាមួយជីលាមកសត្វ ហើយធ្វើការដាំកូនអោយចំកណ្តាលរណ្តៅ និងដោតបង្គោលឬស្សីរួចចងកូនស្វាយជាប់នឹងបង្គោលនោះដើម្បីអោយដើមមានលំនឹង ។ ចន្លោះពីរណ្តៅ ១ប្រវែង ៩ម៉ែត្រ និងពីជួរ១ ទៅ ជួរ១ទៀត ៩ម៉ែត្រ ។

V. ការប្រមូលផល :

កត្តាចាំបាច់បំផុតនៃការប្រមូលផលដើម្បីរក្សាផ្លែប្រកបដោយគុណភាពនិងមានតំលៃខ្ពស់គឺមិនត្រូវទុកផ្លែអោយទុំលើដើមយូរពេកទេ ព្រោះវាអាចបណ្តលអោយមានការបំផ្លាញពីសំណាក់សត្វជ្រើង និងជំងឺផ្សិត ។ ការប្រមូលផលចែកចេញជាពីរប្រភេទ :

- សំរាប់ធ្វើការនាំចេញ
- សំរាប់ការលក់ដូរក្នុងស្រុក ។

សំរាប់នាំចេញភាគច្រើនគេចាប់ផ្តើមប្រមូលផលនៅពេលផ្លែចាស់មិនទាន់ទុំ ដើម្បីងាយក្នុងការលើកដាក់នៅពេលដឹកនាំ ។

សំរាប់ការលក់ដូរក្នុងស្រុកភាគច្រើនគេចាប់ផ្តើមធ្វើការប្រមូលផលនៅពេលផ្លែជិតទុំ ( ផ្លែស្រគៀល) ។ ការប្រមូលផលនៅពេលផ្លែទុំលើដើម ផ្អែមឆ្ងាញ់ជាងផ្លែដែលបេះបន្ទុំ ។

# ដំណាំទៀបខ្មែរ (Custard apple )

ទៀបជាដំណាំឈើហូបផ្លែដែលគេនិយមដាំនៅជុំវិញផ្ទះរឺជាចំការ ។ ផ្លែវាសំបូរទៅដោយទឹកដម និង រសជាតិផ្អែមឆ្ងាញ់ ។ ទៀបមានពីរប្រភេទគឺទៀបស្វិត និង ទៀបបាយ ។ ក្នុងចំណោមប្រភេទទាំងពីរនេះទៀបស្វិតគឺជាប្រភេទទៀបដែលប្រ ជាជនយើងនិយមចូលចិត្តជាទីបំផុត ។

ប្រសិនបើយើងបរិភោគផ្លែទុំ ចំនួន១០០ក្រាមវានឹងផ្តល់ថាមពលចំនួន ៩៣កាឡូរី.ប្រូតេអ៊ីន១.៣ក្រាម. ដែក ០.៩មីលីក្រាម.កាបូនអ៊ីដ្រាត ២៣.៧ក្រាម.កាល់ស្យូម ៤១មីលីក្រាម និង វីតាមីនសេ ( អាស្កូប៊ិច អាស៊ីត) ៤៣ មីលីក្រាម ។

ទៀបមានឈ្មោះវិទ្យាសាស្រ្តថា : Annona squamosa ហើយស្ថិតក្នុងសន្តាន Annonaceae

ឈ្មោះជាភាសាអង់គ្លេស : Sweet sop, Sugar apple ,Custard apple ។

## I – លក្ខណៈរូប:

ជាទូទៅដើមវាមានកំពស់ពី៣ ទៅ ៥ម៉ែត្រ ។ ស្លឹកវាឆ្លាស់គ្នារាងទ្រវែង ពណ៌ខៀវចាស់ប្រវែងពី៨ ទៅ ១៥ស.ម និងទទឹងពី ២ ទៅ៥ស.ម ។ ទងស្លឹកប្រហែលពីទៅ១.៥ស.ម ។ ផ្ការបស់វាមានជាគូរឺតែមួយចេញពីគល់ស្លឹកខ្លីប្រវែងប្រហែល ២.៥ស.ម ។ សំបកផ្លែក្រឡាគ្រើម និង មានអង្កត់ផ្ចិតប្រហែលពី ៥ ទៅ ១០ស.ម ។

## II. ការដាំដុះ :

ការដាំដុះនៅជុំវិញផ្ទះជាលក្ខណៈគ្រួសារ នោះវាជាការងាយស្រួលណាស់ចំពោះដំណាំនេះ ។ ដោយគ្រាន់តែព្រោះគ្រាប់ទៅលើដីសើមវានឹងដុះហើយគាស់យកទៅដាំវាជាការស្រេច ។ ប៉ុន្តែបើគេដាំជាលក្ខណៈចំការដែលមានទ្រង់ទ្រាយធំនោះ មិនមែនជាការងាយស្រួលប៉ុន្មានទេគឺគេត្រូវតែចេះវិធីដាំដុះ និងថែទាំជាចាំបាច់ ។

### ១. ការជ្រើសរើសពូជ:

នៅប្រទេសកម្ពុជាយើងការសិក្សាស្រាវជ្រាវពីដំណាំឈើហូបផ្លែ គឺពុំទាន់បានស៊ីជំរៅនៅឡើយទេ ។ ដូច្នេះការជ្រើសរើសពូជ គឺកសិករ រឺម្ចាស់ចំការជាអ្នកអនុវត្តផ្ទាល់ ។

ទោះជាយ៉ាងណាក៏ដោយការជ្រើសរើសពូជក៏គួរជ្រើសយកតាមលក្ខណៈដូចខាងក្រោម :

- ជ្រើសយកពូជទៀបចេញពីដើមធំល្អ ផ្លែច្រើនគ្មានសត្វល្អិត និងជំងឺ ។
- ជ្រើសយកផ្លែដែលមានទំហំធំ ( ២៥០ ទៅ ៣០០ក្រាម ) និង មានរាងមូលល្អ ។
- ផ្លែមានគ្រាប់តិច និង ទុំល្អ។

- មិនងាយប្រេះសំបក ។

## ២_ ការបណ្តុះគ្រាប់:

ក្រោយពីបានជ្រើសរើសគ្រាប់តាមលក្ខណៈវិនិច្ឆ័យខាងលើនេះហើយ គ្រាប់ទៀបត្រូវយកទៅបណ្តុះនៅក្នុងថ្នាលឬក្នុងកន្ទោងដើម្បីងាយស្រួលក្នុងការយកទៅដាំ ។ ត្រូវកប់គ្រាប់ក្នុងដីជំរៅ១ស.ម និងឃ្លាតគ្នាពី ២ ទៅ ៣ស.ម ក្នុងកន្ទោងតែមួយ ។ ត្រូវស្រោចទឹករហូតដល់ពេលយកទៅដាំ ។

## ៣_ ការរៀបចំដីសំរាប់ដាំ :

កាប់រណ្តៅដែលមាទំហំ០,៥ម៉ែត្របួនជ្រុង ជំរៅប្រហែល០,៥ម៉ែត្រ និងចំងាយពីរណ្តៅ១ទៅរណ្តៅ ១ ទៀតប្រហែលពី ៣ ទៅ៤ម៉ែត្រ ។ កាប់រណ្តៅជាជួររាងចតុកោនកែង ឬជាត្រីកោណក៏បាន ។ ត្រូវជំរះស្មៅអោយបានស្អាតក្នុងចំការដើម្បីកុំអោយមានការដុះប្រកួតប្រជែងនិង កូនដំណាំ ។

## ៤_ ការដាំ:

គ្រាប់ទៀបចាប់ផ្តើមដុះក្នុងរយៈពេលពី ១០ ទៅ ១៥ថ្ងៃ ក្រោយពេលបណ្តុះ។ គេអាចយកវាទៅដាំក្រោយពេលដែលវាមានស្លឹកចាស់ពី ៤ទៅ៦ សន្លឹក ។ ក្នុងពេលនោះគួរបាញ់ថ្នាំសេវីនឬ ម៉ាឡាចុងដើម្បីទប់ស្កាត់នឹងការទិចសន្លឹករបស់សត្វល្អិតឬ ចៃជញ្ជក់ជ័រ និង ដង្កូវស៊ីស្លឹក។

## ៥_ ការដាក់ជី :

ជាទូទៅគេពុំដែលដឹងថាតើដំណាំទៀបនេះត្រូវការជីរបែបណាទេ ហើយកសិករយើងច្រើនតែដាំវាចោលដោយពុំរវល់ថែទាំឡើយ ។ ប៉ុន្តែប្រសិនបើចង់ទទួបានទិន្នផលខ្ពស់ការដាក់ជីជាការចាំបាច់ណាស់ ។ ក្រោយពេលដាំរយៈពេលមួយខែគួរដាក់ជីអាម៉ូញ៉ូមស៊ុលផាតចំនួនពី ៥០ ទៅ ១០០ ក្រាមក្នុងមួយដើមនិង ដាក់ម្តងទៀតចំនួនដូចគ្នានៅចុងរដូវភ្លៀង ។ ចំនួនជីអាចបង្កើនឡើងនៅឆ្នាំបន្ត ។ គួរដាក់ជីគ្រប់មុខនៅពេលទៀបចាប់ផ្តើមផ្កាចំនួនពី២០០_៣០០ ក្រាមក្នុងមួយដើម ហើយត្រូវដាក់២ដងក្នុងមួយឆ្នាំ ។ ត្រូវដាក់ជីនៅជុំវិញគល់ចំងាយ ពី ៣០ ទៅ ៥០ស.ម ដោយយោងទៅតាមអាយុកាលនៃកូនទៀប ។

## ៦_ ការលួសនិងកាប់មែក:

ពេលដើមនៅតូចការកាប់ និងលួសមែកពុំអាចធ្វើទៅបានទេ ព្រោះនាំអោយការលូតលាស់កូនទៀបខ្សោយ ។ ប៉ុន្តែបន្ទាប់ពី២ឆ្នាំក្រោយពេលផ្លែ មែកដែលងាប់និង មែកចាស់គួរកាប់ចេញអោយបានស្អាត ។ បើដើមវាមានអាយុច្រើនគេអាចកាប់ មែកវាចេញអស់ដោយទុកអោយលាស់មែកថ្មីជំនួសវិញ ។

III_ការការពារសត្វល្អិតចង្រៃ និងជម្ងឺ

**១_សត្វល្អិត:**

**_ ដង្កូវបំផ្លាញឬស :** វាស៊ីបំផ្លាញឬសទៀបនៅពេលដែលដើមកំពុងលូតលាស់ធ្វើអោយទៀបស្រពោន និង អាចងាប់បាន ។ គេអាចកំចាត់វាដោយបាញ់ថ្នាំគីមីកសិកម្មចូលទៅក្នុងដីក្បែរគល់ ។

**_ ដង្កូវចោះផ្លែ :**

ដង្កូវនេះវាបំផ្លាញផ្លែ ។ យើងឃើញសរសៃសូត្រមាននៅលើផ្នែកខាងលើនៃផ្លែដែលបំផ្លាញ ។ មេអំបៅពងដាក់នៅលើផ្លែ ឬស្លឹកជិតផ្លែ ។ ដង្កូវចាប់ផ្តើមញាស់ពី ៤ទៅ ៥ថ្ងៃក្រោយពេលពងរួចវាក៏ចាប់ផ្តើមចោះបំផ្លាញផ្លែរហូតដល់វាក្លាយជាដឹកឡឿ នៅក្បែរសំបកផ្លែខាងក្នុង ។ វាក្លាយជាមេអំបៅបន្ទាប់ពីវានៅជាឌឹកឡឿក្នុងរយៈពេល១២ថ្ងៃ។

**_ ដង្កូវដូងកាហ្វេ :** ដង្កូវធំស៊ីរូងរហូតដល់បណ្តូលនៃដើម និងមែកដែលជាកន្លែងរីកធំធាត់របស់វា ។

**_ចៃជញ្ជក់** :មានពពួកចៃជ្ជក់ពណ៌ប្រផេះ និងចៃជញ្ជក់រោមស ជញ្ជក់រុក្ខរសនៅលើស្លឹក និងផ្លែខ្ចីៗ ដែលធ្វើអោយស្លឹកមានពណ៌លឿងរួចក្លាយទៅជាលឿងព្រលែត ។

**វិធានការការពារនិងកំចាត់:**

_ ការប្រមូលផ្លែដែលត្រូវសត្វល្អិតបំផ្លាញយកទៅកប់រឺដុតចោលអោយអស់ ។

_ ប្រសិនបើការបំផ្លាញចាប់ផ្តើមនៅលើស្លឹកដើម ពេលផ្លែនៅខ្ចី គួរបាញ់ថ្នាំការពារ ។

IV-ការប្រមូលផល :

ទៀបចាប់ផ្តើមផ្លែក្នុងរយៈពេលពី ២ទៅ ៤ឆ្នាំក្រោយពេលដាំ ។ ទៀបចាប់ផ្តើមផ្កាពីខែកុម្ភៈដល់ខែមេសា និងចាប់ផ្តើមទុំពីខែកក្កដាដល់ខែកញ្ញា ។ យើងអាចបេះផ្លែយកទៅបន្ទុំនៅពេលដែលវាចាស់ល្អ។ ការកត់សំគាល់ផ្លែទៀបចាស់ ឬខ្ចីគឺពិនិត្យទៅលើសំបកវា ។ ផ្លែទៀបដែលចាស់គឺសំបករបស់វាស្តើងក្រឡារីកធំៗ វានឹងទុំនៅពេលគេទុកវាក្នុងរយៈពេលពីមួយទៅបីយប់ ។ នៅប្រទេសមួយចំនួនដូចជាថៃ ហ្វីលីពីនទៀបក៏ជាផលិតផលនាំចេញក្រៅប្រទេសដែរ ។

# ដំណាំទៀបបារាំង (Soursop)

ទៀបបារាំងមានដើមកំនើតនៅប៉ែកខាងលិចនៃប្រទេសឥណ្ឌា ។ បច្ចុប្បន្ននេះបានរីកដុះដាលនៅស្ទើរតែពេញពិភពលោកទៅហើយ ។

ទៀបបារាំង រឺទៀបបន្លាស្ថិតនៅក្នុងសណ្តាន Annonaceae ដែលមានឈ្មោះវិទ្យាសាស្ត្រថា Annona muricata ។ ឈ្មោះជាភាសាអង់គ្លេស Soursop ។ បើយើងបរិភោគផ្លែទៀបបារាំង ចំនួន១០០ក្រាម អាចផ្តល់ថាមពល៦៣កាល់ឡូរី.ប្រូតេអ៊ីន១.១ក្រាម. ជាតិខ្លាញ់០.១ក្រាម. កាបូអ៊ីដ្រាត១៦.២ ក្រាម . ដែក០.៦មីលីក្រាម កាល់ស្យូម១១មីលីក្រាម ។ ប៉ូតាស្យូម២៦៣មីលីរកាម . ហ្វូស្វ័រ ២៣មីលីក្រាម និងវីតាមីនសេ ២៩មីលីក្រាម ។

I-លក្ខណៈរូប :

ដើមទៀបបារាំងអាចមានកំពស់ប្រហែលពី ៥ ទៅ ៧ម៉ែត្រ ។ ស្លឹកវាមានរាងទ្រវែង រលោងមានពណ៌បៃតងចាស់ប្រវែង ប្រហែលពី ៥ ទៅ ៨ស.ម និងទទឹង ពី ២ ទៅ ៥ស.ម ។ ផ្កាវាធំៗក្លិនប្រហើរ និងដុះចេញពីមែកខាងចុង ។ ត្របកផ្កាធំៗរឹង និងស្រួចចុង ។ ផ្លែវាធំសំបកមានពណ៌បៃតងចាស់និងមានបន្លាពាស់ពេញ។ សាច់ផ្លែមានពណ៌សចែកជាក្លែបតូចៗ មានរស់ជាតិជូរអែម ។ គ្រាប់វាពណ៌ខ្មៅមានប្រវែងប្រហែល២ស.ម ។ ផ្លែដែលធំអាចមានគ្រាប់ប្រហែល២០០ ឬច្រើនជាងនេះ ។

II-ការដាំដុះ :

## ១-ពូជនិងការជ្រើសរើសពូជ :

ទៀបបារាំងមានពីប្រភេទ : ពូជដែលមានរស់ជាតិផ្អែម និងពូជដែលមានរស់ជាតិជូរ-អែម ។ ការជ្រើសរើសពូជសំខាន់បំផុតគឺសំដៅទៅលើ :

- ពូជដែលមានផ្លែច្រើន ធំ ទំងន់ពី១ ទៅ ២ គីឡូក្រាម និងមានគ្រាប់តិច ។
- ផ្លែមានរាងល្អ ហើយមានរសជាតិឆ្ងាញ់។
- ធន់ទ្រាំនឹងជំងឺ និងសត្វល្អិតបំផ្លាញ ។
- ជ្រើសរើសចេញពីដើមដែលដុះលូតលាស់ល្អ ។

### ២. ការរៀបចំបណ្តុះគ្រាប់ :

គ្រាប់ទៀបដែលយកមកបណ្តុះត្រូវមានលក្ខណៈគ្រប់គ្រាន់ដូចខាងលើ ។ ក្រោយពេលយកចេញពីផ្លែ គ្រាប់ត្រូវលាងទឹកអោយស្អាតរួចហាលថ្ងៃ ។ គ្រាប់អាចយកទៅបណ្តុះនៅក្នុងថ្នាលដែលមានលក្ខណៈសមស្រប ។ ចំងាយពីគ្រាប់១ទៅ គ្រាប់១ទៀត គឺប្រហែលពី ៣ ទៅ ៥ ស.ម និង ជំរៅ ១ ស.ម ។ ត្រូវស្រោចទឹកអោយបានជាប់ជាប្រចាំ ។

### ៣. ការរៀបចំដីនិង ការដាំកូនទៀបបារាំង:

ប្រសិនបើដាំនៅជុំវិញផ្ទះសំរាប់បរិភោគគេគ្រាន់តែជីករណ្តៅអោយជ្រៅរួចយកកូនទៀបមកដាំហើយស្រោចទឹកនិងថែទាំវាជាការស្រេច ។ ប៉ុន្តែបើគេដាំជាលក្ខណៈចំការគឺត្រូវភ្ជួរដីអោយបានជ្រៅ រាស់ដីអោយបានស្អាតល្អហើយកាប់រណ្តៅដែលមានទំហំ និងជំរៅដូចគ្នាគឺ៥០ស.ម ។ ចំងាយពីរណ្តៅ ១ ទៅរណ្តៅ ១ ទៀត ប្រហែលពី ៤ទៅ ៧ ម៉ែត្រ ។ ការដាំដុះអាចដាំពេលណាក៏បានតែពេលវេលាដែលល្អគឺដាំក្នុងរដូវវស្សា ដើម្បីបន្ថយការស្រោចស្រព។

III-ការថែទាំនិងការការពារ:

### ១. ការដាក់ជី :

ទៀបបារាំងក៏ដូចជាដំណាំដ៏ទៃទៀតដែរទាមទារនូវការថែទាំជាចាំបាច់ ។ ការដាក់ជីមានឥទ្ធិពលណាស់ក្នុងការធ្វើអោយដំណាំលូតលាស់ ។ កំរិតជីដែលត្រូវប្រើ គឺពី១០០ ទៅ ១៥០ ក្រាមនៃជីអាម៉ូនីញូមស៊ុលផាតដាក់ក្រោយពេលដាំបានមួយខែ និង ដាក់ម្តងទៀតរយៈពេល៦ខែបន្ទាប់មក ។ កំរិតជីត្រូវកើនឡើងរៀងរាល់ឆ្នាំរហូតដល់ដំណាំនេះចាប់ ផ្តើមផ្លែគឺពី ២៥០ ទៅ ៣០០ ក្រាមនៃជីគ្រប់មុខ ។

### ២. ការស្រោចទឹក:

ទឹកក៏មានសារៈសំខាន់ណាស់ដែរចំពោះដំណាំនេះ ។ ការស្រោចទឹកមិនបានគ្រប់គ្រាន់ធ្វើអោយទៀបបារាំងផ្តល់ផ្លែតិច និងមានទំហំតូច ។

### ៣. ការលួសមែក និងការជំរះស្មៅពួនគល់ :

ផ្តល់អត្ថប្រយោជន៍ច្រើនយ៉ាងដូចជា :

- ធ្វើអោយពន្លឺថ្ងៃចាំងមកដល់ក្រោមបានល្អ

- កាប់មែកងាប់ៗ និង មែកដែលមានជំងឺចេញអាចបន្ថយជំរកសត្វល្អិតចង្រៃបានមួយផ្នែក ។
- ជំរះស្មៅក្នុងចំការស្អាតល្អកុំអោយរំខានដំណាំ ។

## ៤_ សត្វល្អិតៈ

ដំណាំនេះត្រូវទទួលរងនូវការបំផ្លាញពីសំណាក់សត្វល្អិតចង្រៃច្រើនមុខដូចជា :

- **ដង្កូវបំផ្លាញឫស** : វិធានការណ៍ បាញ់ថ្នាំពុលគីមីចូលទៅក្នុងដីក្បែរគល់ ។
- **ចៃជញ្ជក់រោមសៈ** វាបំផ្លាញស្លឹកខ្ចីៗនិងផ្លែ ។ ស្លឹកដែលបំផ្លាញប្រែពណ៌ទៅជាលឿងរួញលែងលូតលាស់ វារោមផ្លែពីក្រៅមើលទៅឃើញពណ៌សស្គុស ។ វាជញ្ជក់រុក្ខរសធ្វើអោយផ្លែទៅជាខ្មោចសំបកក្រិន ។វិធានការណ៍ អាចកំចាត់វាដោយប្រើថ្នាំគីមីកសិកម្មដូចជា អាស្វូទ្រីន តាមកំរិតណែនាំរបស់អ្នកបច្ចេកទេស ។
- **ដង្កូវដួង** :ស៊ីរូងបណ្តូលមែក និងដើម ដែលជាកន្លែងវាធំលូតលាស់និងរស់នៅ ។ វិធានការណ៍ កាប់មែកដែលបំផ្លាញ ដោយពពួកនេះយកទៅដុតរឺកប់ចោល ។
- **ដង្កូវរុយ** : ចោះស៊ីផ្លែបណ្តាលអោយផ្លែរលួយ។ វិធានការណ៍ ការខ្ចប់ផ្លែដោយថង់ក្រដាសរឺថង់ផ្លាស្ទិកអាចកាត់បន្ថយការបំផ្លាញដោយសារសត្វចង្រៃនេះ ។

## ៥_ ជំងឺៈ

- **ជម្ងឺរលួយឫស** : វាធ្វើអោយរលួយឫសបណ្តាលអោយរលំដើមហើយងាប់ ។

**វិធានការណ៍** : ត្រូវកាត់ដើមដែលរង ដោយការបំផ្លាញ ដុតរឺកប់ចោល ។

- **អង់ត្រាកណុស** : ធ្វើអោយជ្រុះផ្កានិងផ្លែ ។ ជំងឺនេះក៏អាចកើតមាននៅលើកូនទៀបតូចៗនិង មែកនៃដើមមានផ្លែដែលទើបដុះពន្លកដែរ ។

**វិធានការណ៍** : បាញ់ការពារដោយ ហ្វានជីសាយ ។

- **ជម្ងឺផ្សិតពណ៌ផ្កាឈូក** : ធ្វើអោយមែកទៀបទាំងឡាយបាក់ហើយងាប់ ។ វត្តមាននៃជម្ងឺនេះបានសំដែងអោយឃើញនូវការលូតលាស់ពណ៌សនៅលើកន្លែងដែលឆ្លងដោយជម្ងឺនេះ ។

**វិធានការណ៍** : ត្រូវកាប់មែកដែលឆ្លងដោយជម្ងឺនេះយកទៅកប់រឺដុតចោល ហើយត្រូវបាញ់ថ្នាំគីមីកសិកម្មដែលមានជាតិទង់ដែងការពារជម្ងឺនេះ ។

IV- ការប្រមូលផល :

ទៀបចារាំងផ្តល់ផលក្នុងរយៈពេលពី ៣ ទៅ ៥ឆ្នាំក្រោយពេលដាំ ។ វាផ្កាស្ទើរតែរាល់ខែ ប៉ុន្តែខែសំខាន់ដែលចេញផ្កានោះគឺខែឧសភា និងខែមិថុនា ហើយទុំនៅខែវិច្ឆិកានិងខែធ្នូ។ គេបេះវានៅពេលដែលវាចាស់ល្អក្រឡាវិកសំបុរខៀវស្រាល ។ វានឹងទុំក្រោយរយៈពេលបេះពី ៣ ទៅ៥ថ្ងៃ ។ ការប្រមូលផលគឺធ្វើដោយដៃជៀសវាងការធ្លាក់ឬធ្វើអោយជាំផ្លែដែលបណ្តាលរលួយពេលវាទុំ ។

# ដំណាំត្របែក (Guava)

ត្របែកគឺជាផ្លែឈើម្យ៉ាងដែលប្រជាជនក្មេងចាស់ប្រុសស្រីនិយមចូលចិត្តបរិភោគ ។ ដំណាំនេះត្រូវបានដាំដុះស្ទើរតែគ្រប់ ទីកន្លែងក្នុងប្រទេសកម្ពុជាយើង ។ វាឋិតនៅក្នុងសណ្ឋាន Myrtaceae និងមានឈ្មោះវិទ្យាសាស្ត្រថា Psidium guajava ឈ្មោះជាភាសាអង់គ្លេស Guava ។ ត្របែកមានច្រើនប្រភេទ ។ ប៉ុន្តែយោងតាមពណ៌សំបុរនៃសាច់ផ្លែគេចែកវាចេញជាពីរ គឺត្របែកសាចក្រហម និងត្របែកសាច់ស ។ ផ្លែត្របែកសំបូរទៅដោយវីតាមីន A និង C ដែលជាជំនួយយ៉ាងសំខាន់សំរាប់រាងកាយមនុស្សយើង។

ខាងក្រោមនេះគឺជាតារាងបង្ហាញអំពីកំរិតជីវជាតិក្នុងផ្លែត្របែក ១០០ ក្រាម :

| ជីវជាតិ | ប្រភេទ | |
|---|---|---|
| | សាច់ក្រហម | សាច់ស |
| ថាមពល កាឡូរី | ១២៤ | ៩៩ |
| ប្រូតេអ៊ីន ក្រាម | ១ | ១.២ |
| ប្រេង ក្រាម | ០.៤ | ០.៤ |
| កាល់ស្យូម មីលីក្រាម | ៣៣ | ២២ |
| ហ្វូស្វ័រ មីលីក្រាម | ២៨ | ៣៤ |
| ដែក មីលីក្រាម | ០.៦ | ០.៨ |
| សូដ្យូម មីលីក្រាម | ៧ | ២ |
| វីតាមីន A អ៊ីអ៊ុយ | ១០៥ | ៦៥ |
| វីតាមីន C មីលីក្រាម | ១២៦ | ១០៤ |
| កាបូអ៊ីដ្រាត ក្រាម | ៣២.៥ | ២៥.៤ |
| សែលុយឡូស ក្រាម | ៥.៧ | ៥.០ |
| ប៉ូតាស្យូម ក្រាម | ២៥៤ | ៣៦០ |

I. លក្ខណៈរូប

ជាទូទៅដើមវាមានកំពស់ពី ៣ ទៅ៥ម៉ែត្រ បែកមែកសាខានិងលូតលាស់លឿន ។ ដើមត្របែកអាចមានអង្កត់ផ្ចិតពី១០ទៅ៣០ស.ម ។ ស្លឹកវាងទ្រវែង ហើយគ្រែមមានប្រវែងប្រហែលពីទងស្លឹកជាគូរឬទោល ។ ផ្លែវាមានរាងមូលរឺមូលទ្រវែង និងមានទំងន់ប្រហែលពី ៣០ ទៅ ៣៥០ ក្រាម ដែលអាស្រ័យទៅតាមប្រភេទពូជ ។

II – ការដាំដុះ :

**១. អំពីពូជ:**

ការជ្រើសរើសពូជត្របែកក៏ដូចជាដំណាំដ៏ទៃទៀតដែរ គឺធ្វើយ៉ាងនាគំរូវទៅតាមការនិយមចូលចិត្តរបស់អ្នកទិញ ។ ប៉ុន្តែធ្វើយ៉ាងណាត្រូវតែអនុវត្តទៅតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម :

- រើសផ្លែដែលទុំចេញពីដើមដែលយើងយល់ថាគ្មានចំងឺ ។
- រើសពូជដែលធន់ទ្រាំនឹងជំងឺ និងសត្វល្អិត
- រើសពូជដែលមានគ្រាប់តិច ហើយមានសាច់ក្រាស់ផ្តល់ទិន្នផលខ្ពស់ ។

**២. ការបណ្តុះគ្រាប់:**

ត្រូវលាងគ្រាប់អោយបានឆាប់និងស្អាតបន្ទាប់ពយកចេញពីផ្លែ។ បើអាចដាំបានឆាប់កាន់តែល្អដើម្បីធានានូវដំណុះគ្រាប់ ។ យើងអាចយកគ្រាប់ពូជទៅសាបនៅក្នុងរងដែលត្រៀមរួច ។ សាបតាមចង្អូរដែលឆូតនៅលើរងជំរៅប្រហែលពី ០.៥ ទៅ ១ស.ម ហើយត្រូវសាបគ្រាប់ឃ្លាតពីគ្នាប្រហែលពី ២ ទៅ ៣ស.ម ។ ត្រូវស្រោចទឹកអោយបានជាប់ជាប្រចាំ ។ ត្រូវបាញ់ថ្នាំកូនត្របែកការពារសត្វល្អិត និងជំងឺ ជាពិសេសជំងឺអង់ត្រាក់ណុស ។ ថែទាំនិងការពាររហូតដល់វាមានអាយុប្រហែលមួយឆ្នាំទើបយកវាទៅដាំ ។

ការផ្សាំ និងបំបៅមែកក៏ជាវិធីមួយដែលគេតែងអនុវត្តជាញឹកញាប់ក្នុងការដាំដុះដំណាំនេះដែរ ។ ព្រោះវាឆាប់ផ្តល់ផលជាងការដែលយើងដាំដោយគ្រាប់ ។

**៣. ការរៀបចំដីនិងការដាំដុះ :**

ចំពោះការដាំជាលក្ខណៈគ្រួសារវាមានការងោយស្រួលច្រើនជាងការដាំដុះដែលមានទ្រង់ទ្រាយធំ ។ ត្រូវកាប់រណ្តៅដែលមានទំហំ និងជំរៅល្មម ដាក់ជីធម្មជាតិទ្រាប់បាតរណ្តៅ រួចយកកូនត្របែកមកដាំជាការស្រេច ។ ចំពោះការដាំជាលក្ខណៈចំការធំៗត្រូវភ្ជួររាស់អោយបានជ្រៅរាស់អោយបានម៉ត់ល្អ។ កាប់រណ្តៅដែលមានទំហំនិងជំរៅ

ដូចគ្នាគឺ ៥០ស.ម ។ មុនដាំត្រូវដាក់ជីធម្មជាតិក្នុងបាតរណ្តៅ ។ ប្រសិនបើអាកាសធាតុក្តៅខ្លាំងគួរគ្របគល់កូន ត្របែកដើម្បីរក្សាសំណើម និងជៀសវៀងកុំអោយវាស្រពោន ។ រណ្តៅនីមួយៗត្រូវឃ្លាតគ្នាចំងាយប្រហែលពី ៤ ទៅ ៥ម៉ែត្រ ។

**៤_ការដាក់ជី :**

ដើម្បីអោយការលូតលាស់បានល្អ កាដាក់ជីជាការចាំបាច់ណាស់ចំពោះគ្រប់ដំណាំទាំងអស់ ។ ចំពោះត្របែកនៅឆ្នាំទី១ បន្ទាប់ពីដាំត្រូវប្រើជីអាមូញ្ញូមស៊ុលផាតក្នុងកំរិតពី ១០០ ទៅ ១៥០ ក្រាម ក្នុង១ដើមដោយដាក់ជុំវិញគល់ហើយក្នុងមួយឆ្នាំដាក់ពីរដង ។ ដាក់លើកទី១គឺក្រោយពេលដាំបានមួយខែនិងលើកទី២ គឺរយៈពេល ៦ ខែបន្ទាប់ពីការដាក់លើកទី១ ។ កំរិតជីដែលត្រូវប្រើគឺកើនឡើងទៅតាមអាយុកាលរបស់ដើមត្របែក ។ នៅពេលដែលត្របែកចាប់ផ្តើមផ្កាគឺត្រូវប្រើពី ៣០០ ទៅ ៥០០ ក្រាមនៃជីប្រភេទគ្រប់មុខតែកំរិតជាតិអាសូត និងប៉ូតាស្យូម ត្រូវមានច្រើនជាងគេ ។

**៥ _ ការលួសមែក :**

ការលួសមែកមានសារៈសំខាន់ណាស់ចំពោះដំណាំឈើហូបផ្លែ ។ ការលួស និងកាប់មែកចាស់ៗចេញផ្តល់ផលប្រយោជន៍ច្រើនយ៉ាងដូចជា :

- ធ្វើអោយដើមលូតលាស់ល្អជាងធម្មតា។
- បន្ថយជំរកសត្វល្អិត និង ជំងឺ ។
- បន្ថយភាពស៊ុបទ្រុបក្នុងចំការ ។
- ធ្វើអោយផ្លែធំជាងដើមដែលមិនបានកាប់មែកចាស់ ។ ការកាប់ដើមចាស់និងមែកចាស់ៗចេញអាចធ្វើក្នុងរយៈពេលពី ៣ ទៅ ៤ ឆ្នាំម្តង ។

**៦_សត្វល្អិតនិងជំងឺ :**

**ក_សត្វល្អិត**

ដំណាំគ្រប់ប្រភេទរមែងទទួលរងនូវការបំផ្លាញពីសំណាក់សត្វល្អិតចង្រៃជាដរាប ។ យ៉ាងណាមិញចំពោះដំណាំត្របែក ក៏ដូច្នេះដែរ សត្វល្អិតចង្រៃដែលបំផ្លាញវាមានច្រើនប្រភេទណាស់ ។

**_ ដង្កូវរុយចោះផ្លែ**

នេះជាប្រភេទសត្វល្អិតចង្រៃដែលបំផ្លាញផ្លែ ។ ដង្កូវរបស់វាចោះចូលទៅក្នុងផ្លែទុំដែលធ្វើអោយយើងមិនអាចបរិភោគបាន ។ គេអាចបាញ់ថ្នាំ ម៉ាឡាចុងការពារពីរសប្តាហ៍មុនផ្លែទុំ ។

**- សត្វល្អិតរាងដូចក្រម៍ Chinese wax seale :**

វាបំផ្លាញនៅលើស្លឹក មែកនិងមែកតូចៗ ។ ការបំផ្លាញខ្លាំងរបស់វា បណ្តាលអោយស្លឹកឡើងស្ងួត និងមិនសូវមានផ្លើរមានផ្លែតូចៗ ។

**វិធានការណ៍:**

មធ្យោបាយការពារ គឺបាញ់ថ្នាំគីមីកសិកម្មប្រភេទម៉ាឡាចុង នៅពេលឃើញការបំផ្លាញលើកដំបូង ។ គេអាចបាញ់ថ្នាំកំចាត់បានដែរ ដោយថ្នាំម៉ាឡាចុង ឬ ថ្នាំគីមីកសិកម្មដ៏ទៃទៀត ។ ត្រូវកាប់មែកដែលរងការបំផ្លាញចេញ រួចដុតឬកាប់ចោល ។

**- សត្វចាបនិងជ្រើង :** នេះក៏ជាឧបសគ្គមួយសំរាប់ដំណាំត្របែកដែរក្រៅពីសត្វល្អិត ព្រោះវាបំផ្លាញផ្លែដែលទុំ ។

**វិធានការណ៍ :**

- រុំផ្លែនឹងក្រដាស់ឬថង់ប្លាស្ទិកព្រោះផ្លែត្របែកទុំសាយក្លិនក្រអូបដែលអាចទាក់ទាញពួកសត្វទាំងនេះ ។
- ប្រមូលផលអោយទាន់ពេលវេលា ដោយកុំទុកអោយទុំពេកនៅលើដើម។

**ខ- ជំងឺ :** គេសង្កេតឃើញមានជម្ងឺខ្លះៗចំពោះដំណាំត្របែក ។

**- ស្នាមអុចៗនៅលើផ្លែនិងស្លឹក :**

គឺជាការបង្ករឡើងដោយសារពួកសែប៉ារាស៊ីត ។ ជំងឺនេះច្រើនកើតឡើងដោយនៅពេលអាកាសធាតុសើមខ្លាំងដែលជាហេតុធ្វើអោយផ្លែមានស្នាមអុចៗខុសពីធម្មតា ។

**វិធានកាណ៍:**

- អាចប្រើថ្នាំ ហ្វានជីសាយ ដែលមានជាតិស្ពាន់ធ័រ ។
- អង់ត្រាកណូសឺជម្ងឺរលួយនៅលើផ្លែ :បណ្តាលមកពីមេរោគពពួកផ្សិត ។

រោគសញ្ញាមានពីរយ៉ាងគឺ :

១-ការលេចចេញនៅចំនុចដូចក្រម៍ដំបៅអុចៗពេញសំបកផ្លែ ។ កន្លែងអុចៗនោះមូលស្ងួតហើយកាន់តែរាលដាលធំឡើងៗ ។ លើកលែងតែការរាលដាលមានតិចតួចវាមិនសូវជះឥទ្ធិពលទៅលើភាពខាងក្រៅនៃផ្លែប៉ុន្មានទេក្នុងករណីនេះផ្លែដែលបង្កឡើងដោយជម្ងឺនេះអាចធ្វើអោយផ្លែមានទំហំតូចកំពឹកកំពក និងបន្ទាបមកក្រៀម ។

២-ជម្ងឺបង្កដោយអង់ត្រាកណូសមួយទៀត រីនៅកន្លែងដុំបៅអុចៗនោះរលួយ ។ គេអាចមើលឃើញការបំផ្លាញនេះចំពោះផ្លែទុំតែប៉ុណ្ណោះ ។ នៅក្នុងលក្ខខ័ណ្ឌអាកាសធាតុសើមខ្លាំងគេអាចមើលឃើញស្ព័រជា

ច្រើនពណ៌ត្នូឡាបព្រលែតនៅលើមុខដំបៅរលួយអុចៗនោះ ។ ស្ព័រនេះអាចចំលងទៅរុក្ខជាតិដំទៃទៀតរឺ ផ្លែដ៏ទៃ ទៀតបាន ។

**វិធានការណ៍** : ប្រើថ្នាំគីមីកំចាត់ជម្ងឺផ្សិតបាញ់ទៅលើដើមរឺអាចប្រើល្បាយកំបោរសនិងសាច់ជូរខៀវក៏បានដែរ ។

III- ការប្រមូលផល :

ជាទូទៅត្របែកចាប់ផ្តើមផ្លែក្នុងកំឡុងពេលពី ២ ទៅ៣ ឆ្នាំក្រោយពេលដាំ ។ ការប្រមូលផលច្រើនធ្វើដោយដៃឬទុំពូក ។ នៅប្រទេសជឿនលឿនមួយចំនួនដូចជាប្រទេសថៃ ហ្វីលីពីន ផ្លែត្របែកទុំគេយកទៅកែច្នៃទៅជាទឹកផ្លែឈើកំប៉ុងដែលប្រជាជនភាគច្រើននៅលើពិភពលោកនិយមចូលចិត្ត ។

# ដំណាំខ្នុរ (Jackfruit)

ដំណាំខ្នុរមានឈ្មោះវិទ្យាសាស្ត្រ Artocarpus heterophyllus lam ស្ថិតក្នុងសណ្ឋាន Moraceae រឺ Mulberry ។ ដំណាំនេះត្រូវបានគេនិយមដាំនៅតំបន់ត្រូពិច ។ ឈ្មោះជាភាសាអង់គ្លេស Jackfruit ឈ្មោះជាភាសាបារាំង Jack ។ ដំណាំខ្នុរមានដើមកំណើតនៅភាគខាងលិចប្រទេសឥណ្ឌា ។ ដំណាំខ្នុរមានពីរប្រភេទ គឺៈខ្នុរណាំង និងខ្នុរបាយស្រោ ។

សមាសធាតុនៅក្នុងផ្លែខ្នុរចំនួន ១០០ក្រាម នៃផ្នែកដែលអាចហូបបាន :

| សមាសធាតុ | | ផ្លែ | | គ្រាប់ |
|---|---|---|---|---|
| | | នៅខ្ចី | ទុំ ( សាច់) | |
| សំណើម | ភាគរយ | ៨៥,២ | ៧២,៤ | ៥៧,៦ |
| ថាមពល | កាឡូរី | ៥១ | ៩៧ | ១៤៣ |
| ប្រូតេអ៊ីន | ក្រាម | ២,០ | ១,៤ | ៥,៦ |
| ប្រេង | ក្រាម | ០,៦ | ០,៤ | ០,៦ |
| កាបូនអ៊ីដ្រាត | ក្រាម | ១១,៥ | ២៤,០ | ៣៤,៩ |
| សែលុយឡូស | ក្រាម | ២,៦ | ០,៨ | ១,៤ |
| កាល់ស្យូម | មីលីក្រាម | ៥៣ | ២៣ | ២៣ |
| ផូស្វ័រ | មីលីក្រាម | ២០ | ១៨ | ៨០ |
| ដែក | មីលីក្រាម | ០,៤ | ១,១ | ០,៨ |
| សូដ្យូម | មីលីក្រាម | ៣ | ២ | ៣ |
| ប៉ូតាស្យូម | មីលីក្រាម | ៣២៣ | ៤០៧ | ៦៧៣ |
| វីតាមីនអា | I.U | ៣០ | ១៧៥ | - |
| វីតាមីនសេ | មីលីក្រាម | ១២ | ៥ | ១ |

I_លក្ខណៈរូប :

**ដើម** : ខ្នុរគឺជារុក្ខជាតិដែលមានស្លឹកបៃតងជានិច្ច ។ ដើមមានទំហំល្មមមានកំពស់ពី៨ទៅ ១៥ ម ហើយរាងមូលឈត្រង់មិនសូវបែកមែកសាខា ។ ដើមខ្នុរមានសំបកពណ៌ប្រផេះត្នោត និងមានជ័រពណ៌សហូរចេញពីដើមនៅពេលគេកាប់វា ។

**ស្លឹក** : ស្លឹកខ្នុរក្រាស់ថិតនៅឆ្លាស់គ្នាលើមែកនិមួយៗនិងមានរាងមូលទ្រវែង ។ ស្លឹកផ្នែកខាងលើមានសភាពរលោងពណ៌បៃតងចាស់ឯផ្នែកខាងក្រោមមានពណ៌បៃតងខ្ចីស្រអាប់ ។ ទំហំស្លឹកមានបណ្តោយប្រវែងពី ១០ ទៅ១៥ ស.ម និង ទទឹងពី ៥ ទៅ ១០ស.ម ។ ចំណែកឯស្លឹកខ្ចីមានពណ៌លឿងរឺបៃតងព្រលែត ។

**ផ្លែ** : ផ្លែខ្នុរមានសំបកក្រាស់ ពណ៌បៃតងព្រលែតនៅពេលខ្ចី និងពណ៌លឿងបៃតងនៅពេលទុំព្រមទាំងមានបន្លាស្រួចៗ ។ ទំហំនៃផ្លែធំរឺតូចអាស្រ័យទៅនឹងពូជ ។ ផ្លែមានរាងមូលទ្រវែងមានបណ្តោយប្រវែងពី២៥ ទៅ ៦០ស.ម និង អង្កត់ផ្ចិតពី២៥ទៅ៥០ស.ម ។ ផ្លែខ្នុរអាចមានទំងន់រហូតដល់ ៣៥ទៅ៥០ គ.ក្រ ។ ផ្លែខ្នុរទុំមានក្លិនក្រអូបរសជាតិផ្អែមប្រកបដោយទឹកដមយ៉ាងឆ្ងាញ់ពិសារ ។ ផ្លែខ្នុរទុំមានសាច់ក្រាស់ពណ៌លឿង ហើយមានគ្រាប់នៅខាងក្នុង ។ គ្រាប់ខ្នុរផ្ទុកទៅដោយអាមីដុង ( ជាតិម្សៅ) ។ គ្រាប់ខ្នុរមានរាងមូលទ្រវែងបណ្តោយប្រវែងពី២,៥ ទៅ ៤,០ស.ម និង អង្កត់ផ្ចិតពី១,១ ទៅ ២,៣ ស.ម ។

II –លក្ខខ័ណ្ឌដីនិងអាកាសធាតុសមស្រប

ដើមខ្នុរអាចលូតលាស់បានល្អនៅតំបន់អាកាសធាតុត្រូពិចដែលមានទឹកភ្លៀងគ្រប់គ្រាន់ ។ វាជាដំណាំដែលអាចដាំបានលើដីគ្រប់ប្រភេទ ។ ប៉ុន្តែដីដែលល្អបំផុតសំរាប់ដំណាំខ្នុរគឺដីមានជីជាតិនិងស្រោះទឹកល្អ ។

III-ការអនុវត្តនៅក្នុងថ្នាលបណ្តុះ

ការផ្សាំរឺបំបៅចំពោះដំណាំខ្នុលមិនសូវមានប្រសិទ្ធភាពប៉ុន្មានទេ ។ ហេតុដូច្នេះហើយទើបគេនិយមដាំវាដោយគ្រាបវិញ ។

**១_ការរៀបចំគ្រាប់ពូជនិងដំណុះ :**

ការរៀបចំគ្រាប់សំរាប់ដាំគួរតែមានទំនាក់ទំនងយ៉ាងល្អទៅនឹងដើមមេ ពោលគឺទំហំផ្លែ និងចំនួនគ្រាប់ ។ គ្រាប់ដែលយកចេញពីផ្លែត្រូវបកសំបកគ្រាប់ខាងក្រៅចេញរួចលាងទឹកអោយស្អាត ។ គ្រាប់សំរាប់ដាំគួរជ្រើសរើសគ្រាប់ដែលមានទំហំធំព្រោះតាមការសិក្សាកន្លងមកបានបង្ហាញថាគ្រាប់ដែលមានទំហំធំ ហើយធ្ងន់មានដំណុះ និងគុណភាពល្អជាងគ្រាប់ដែលមានទំហំតូច ។ គ្រាប់ដែលយកចេញពីផ្លែភ្លាមអាចយកទៅដាំភ្លាម ។ តាមការសិក្សា

នៅប្រទេសឥណ្ឌាបានបង្ហាញថា គ្រាប់ខ្នុរដែលយកចេញពីផ្លែហើយក្រយកទៅដាំនោះភាគរយនៃដំណាំ និង ថយចុះ ឯការដុះពន្លកមានរយៈពេលយូរ។

**២. ការបន្តពូជ :**

**ក. ការដាំដោយគ្រាប់:**

ខ្នុរស្លិកនៅក្នុងក្រុមរុក្ខជាតិដែលដុះលូតលាស់ដោយគ្រាប់ ។ រីឯវិសាស្ត្រនៅក្នុងការផ្សាំ រឺបំប៉ៅមិនសូវទទួលបានជោគជ័យប៉ុន្មានទេ។ នៅប្រទេសជាច្រើនការដាំដោយគ្រាប់មានតំលៃថោកនិងមានលក្ខណៈងាយជាង ។

**ខ. ការដាំដោយមែកផ្សាំរឺបំប៉ៅ:**

តាមការសិក្សានៅប្រទេសភីលីពីនបានអោយដឹងថាលទ្ធផលល្អគឺការផ្សាំរឺបំប៉ៅលើមែកដែលមានទំហំពី ៣ ទៅ ៤,៥ស.ម ដោយជៀរសំបកប្រវែងពី១ ទៅ១,៥ស.ម រួចយកដីលាយលាមកសត្វស្ងួតមកបិទ ដោយយកក្រណាត់រឺស្រកីដូងមករុំអោយបានជិតល្អពីខាងក្រៅ ។ ស្រោចទឹកកន្លែងផ្សាំអោយសើមជានិច្ច ។ បើកន្លែងផ្សាំ ដុះឫសច្រើនល្មមត្រូវកាត់យកទៅផ្សាំក្នុងកន្ថោងរឺ យកទៅដាំក្នុងចំការតែម្តង ។

**៣. ការថែទាំកូន:**

នៅឆ្នាំដំបូង កូនខ្នុរមានការដុះលូតលាស់យឺត ។ នៅឆ្នាំបន្ទាប់វាអាចដុះលូតលាស់បានពី២ ទៅ ៣ ស.ម ក្នុងរយៈពេលមួយខែ ។ កូនខ្នុរអាចដុះលូតលាស់បានយ៉ាងល្អនៅដីគ្រប់ប្រភេទជាពិសេសប្រភេទដីកន្តែងល្បាយដីឥដ្ឋមានជីជាតិ ។ ជាការប្រសើរយើងចាំបាច់ត្រូវប្រើប្រាស់ជីកំប៉ុស្ត៍ រឺ ជីលាមកសត្វលាយជាមួយដីមុនដាំកូនខ្នុរ ហើយត្រូវស្រោចស្រពទឹកអោយបានគ្រប់គ្រាន់។ត្រូវបន្ថែមជីអាសូតថែមទៀតក្នុងរយៈពេលពី ២ទៅ៣ ខែម្តង។

IV-ការអនុវត្តន៍បច្ចេកទេសដាំដុះ :

**១. ការរៀបចំដី :**

មុននឹងដាំកូនខ្នុរយើងត្រូវរៀបចំដីអោយបានល្អដោយកាប់ដីអោយបានជ្រៅ បន្ទាប់មកយើងត្រូវកាប់រណ្តៅដែលមានទំហំមធ្យម ។ ការរៀបចំដីគួរតែធ្វើឡើងនៅដើមរដូវភ្លៀងងាយស្រួលក្នុងការដាំកូន ។

**២. ការដាំ :**

មុននិងដាំកូនខ្នុរត្រូវប្រព្រឹត្តឡើងនៅពេលព្រឹកឬពេលល្ងាច។ មុននឹងដាំកូនខ្នុលរក្នុងការណ្តៅត្រូវលាយច្របល់ជីធម្មជាតិជាមួយនឹងដីបាតរណ្តៅ ។ ការដាំកូនខ្នុរត្រូវធ្វើឡើងដោយប្រុងប្រយត្ន័ជៀសវៀងធ្វើអោយដាច់ឬបាក់ឫស ។ នៅក្នុងថ្នាលមិនត្រូវទុកឫសកំណើតរបស់វាអោយលូតលាស់វែងរហូតដល់ធ្លុះកន្ថោងឬធុងបណ្តុះនោះទេ ។ មុននឹងដាំគួរកាត់ស្លឹកចាស់ពាក់កណ្តាលចេញដើម្បីបន្ថយការរំហួតទឹកក្នុងដើម ។ ការកាត់ស្លឹកនេះគួរតែ

ធ្វើឡើងនៅពេលដែលកូនខ្នុរនៅក្នុងថ្នាល្អឹងកន្ទោង។
ការដាំគូនខ្នុរអាចអាចប្រព្រឹត្តទៅជារៀងរាល់ខែក្នុង លក្ខខ័ណ្ឌដីមិនស្ងួតស្ងួតក្រៀម ។ បន្ទាប់ពីដាំកូនរួចចាំបាច់ត្រូវស្រោចទឹក ។ ការដាំកូនកូនខ្នុរល្អបំផុតគឺនៅដើមរដូវវស្សាពីព្រោះយើងមិនចាំបាច់ស្រោចទឹក ។ ប៉ុន្តែនៅរដូវក្តៅវិញបន្ទាប់ពីដាំចាំបាច់ត្រូវស្រោចទឹកដោយប្រើធុងស្រោចទឹក រហូតដល់កូនខ្នុរលូត លាស់ល្អ។

**៣_ ការដាំដំណាំចំរុះ :**

នៅក្នុងចំការខ្នុរគេអាចដាំចំរុះលាយជាមួយដមណាំឈើហូបផ្លែដ៏ទៃទៀតបានដូចជា :ល្ហុង,កាហ្វេ ។ល។ គេក៏អាចដាំដំណាំយក ផលប្រចាំឆ្នាំផ្សេងៗទៀតបានដែរដូចជាពោត,សណ្តែក,ល្ង ហើយវាក៏ជាដំណាំគំរបដីដែរ ។ ការដាំដំណាំនៅចន្លោះកូនខ្នុរនឹងត្រូវបញ្ឈប់នៅពេលដែលកុនខ្នុរធំ ។

**៤_ ការស្រោចស្រព :**

ការស្រោចស្រពប្រព្រឹត្តិទៅភ្លាមបន្ទាប់បីដាំ ។ការស្រោចស្រពបន្តរហូដល់វាមានអាយុពី ១ ទៅ២ឆ្នាំ ។ បន្ទាប់មកការរេសាចស្របត្រូវបន្ថយ ។ នៅចុងរដូវភ្លៀងត្រូវគេកំទេចសំរាមរីស្លឹកឈើស្ងួតៗក្បែរគល់ដើម្បីការពារកុំអោយឆាប់ស្ងួតដី ។

**៥_ ការដាក់ជី :**

ការដាក់ជីអាចប្រព្រឹត្តទៅបន្ទាប់ពីដាំបានរយះពេល១ខែ ។បរិមាណដែលត្រូវដាក់គឺជីអាម៉ូញ៉ូមស៊ុលផាតចំនួនពី១០០ទៅ១៥០ក្រាមក្នុងមួយដើម នឹងដាក់ជីម្តងទៀតនៅពេល៦ខែបន្ទាប់ពីការដាក់លើកទីមួយ។ ចំនួននៃការដាក់ជីត្រូវកើនឡើងស្របទៅនិងការរីកធំធាត់របស់កូនរុក្ខជាតិ ។ នៅពេលដែលដើមខ្នុរចេញផ្កាផ្លែលើកដំបូងត្រូវដាក់ជីគ្រប់មុខចំនួនពី០,៥ ទៅ១គ,ក្រក្នុងមួយដើម ។ នៅពេលដែលដើមខ្នុរមានអាយុពី១៥ ទៅ ២០ឆ្នាំ ត្រូវដាក់ជីគ្រប់មុខចំនួនពី ២ទៅ ៣គ,ក្រ សំរាប់ខ្នុរមួយដើម ។

V-ការការពារសត្វល្អិតចង្រៃ និងជំងឺ

**១_ ជំងឺ :**

ដំណាំខ្នុរច្រើនរងការបំផ្លាញដោយជំងឺផ្សិតឈ្មោះ Rhizopus nigricans បណ្តលអោយរលួយផ្កា, ជម្ងឺផ្សិតពណ៏ផ្កាឈូក ឈ្មោះ C.salmonicolar និងជម្ងឺឈ្មោះ Rhizoctonia koleroga ធ្វើអោយផ្លែប្រេះ ។

**វិធានការការពារ និង កំចាត់ :**

កាប់មែក ស្លឹក និងផ្លែ ដែលកើតជំងឺនេះដុត រឺកប់ចោល រឺក៏អាចប្រើថ្នាំគីមីកសិកម្ម Cupravit រឺល្បាយកំបោរស−សាច់ជូរខៀវក៏បាន ( Bordeaux mixture ) ។

**២. សត្វល្អិតចង្រៃ :**

- **ដង្កូវរុយ** : ការបំផ្លាញដោយដង្កូវរុយច្រើនកើតមាននៅលើផ្លែ ។ ដំបូងរុយពងដាក់លើសំបកផ្លែខ្នុរ បន្ទាប់ ៥ ទៅ ៦ថ្ងៃក្រោយមកពងដង្កូវរុយញាស់ហើយស៊ីបំផ្លាញសាច់ខាងក្នុងផ្លែ ។ ផ្លែដែលត្រូវបំផ្លាញដោយសារដង្កូវរុយប្រហែលជា៥០% ហើយផ្លែត្រូវខូចជ្រុះនៅមុនពេលទុំ ។ ក្រោយពីបានបំផ្លាញ ៩ថ្ងៃ ដង្កូវក៏ស្ទូតចុះមកដីដោយ ខ្សែ របស់វាពេលនោះវាក៏ក្លាយជាដឹកក្នុងដី ។

**វិធានការការពារ និងកំចាត់ :**

ត្រូវបេះផ្លែដែលរងការបំផ្លាញនេះដុតចោល រឺបាញ់ថ្នាំម៉ាឡាថុងដើម្បីការពារចំពោះផ្លែខ្ចីៗ ។

VI-ការប្រមូលផល :

គេប្រើកាំបិត ឬកន្ត្រៃមុតកាត់ទងផ្លែដោយទ្រផ្លែទាំងមូលកុំអោយធ្លាក់មកដី ។ ចំពោះដើមខ្នុរដែលខ្ពស់ត្រូវកាត់ផ្លែដាក់ក្នុងកន្ត្រក ឬច្រកបាវសម្រូតខ្សែទំលាក់ចុះមកដីថ្នមៗ ។ ថ្វីត្បិតតែផ្លែខ្នុរធន់ និងការប៉ះទង្គិចក៏ដោយការធ្វើមិន អោយមានជាំនៅលើផ្លែជាការប្រសើរ ព្រោះយើងអាចលក់វាបានក្នុងតំលៃថ្លៃ ។

# ដំណាំដូង (Coconut)

I– គោលបំណង :

ដូងបានផ្តល់ផលប្រយោជន៍យ៉ាងច្រើនដល់មនុស្សជាតិដែលគេដាំពាសពេញពិភពលោកក្នុងគោលបំណងសំខាន់គឺដើម្បីយកផ្លែ ។ ក្រៅពីផ្លែដូងផ្នែកដ៏ទៃទៀតក៏ត្រូវបានមនុស្សយើងយកមកប្រើប្រាស់ដែរដូចជា ផ្កា គេអាចគៀបយកទឹកធ្វើជា ស្ករ ស្រា និង ទឹកខ្មេះជាដើម ។ ឫសវាគេអាចយកទៅធ្វើជាឱសថ ដើមវាធ្វើសំណង់បន្ទាប់បន្សំ ស្លឹកវាគេអាចដេរជាម្លូក ឬ ប្រកផ្ទះជាបន្ថោះអសន្នបាន ហើយកំពូលរីគមវាអាចយកមកធ្វើជាបន្លែបាន។ ល ។ ដូច្នេះដូងសមគេអោយឈ្មោះថាជារុក្ខជាតិប្រើប្រាស់បានមួយរយមុខបន្ទាប់ពីត្នោត ដែលកសិករយើងនិយមចូលចិត្តដាំជាងគេ ។

II- រុក្ខវិទ្យា :

**១. ដើមកំនើត:**

ភាគច្រើននៃដាំណាំសុតតែមានប្រភពដើមរបស់វា ។ តាមរយៈការស្រាវជ្រាវរកឃើញពូជដែលដុះខ្លួនឯងនៅក្នុងព្រៃ ។ ក៏ប៉ុន្តែដំណាំដូងជាដំណាំមួយដែលប្លែកពីគេព្រោះគេពុំអាចដឹងកន្លែងកំណើតពិតប្រាកដរបស់វា។ គេប៉ាន់ស្មានថាប្រហែលវាមានដើមកំណើតនៅអាស៊ីអាគ្នេយ៍ ហើយការប៉ាន់ស្មាននេះគេចាត់ទុកថាអាចត្រឹមត្រូវច្រើនរហូតដល់សព្វថ្ងៃ នេះ ។

**២. លក្ខណៈពិសេស :**

ដូងអាចមានកំពស់ ២៥ ទៅ៣០ ម៉ែត្រ។ តួដើមរលោងមានថ្នាំងជាកង់ៗ ហើយខាងគល់រីកធំ និងខាងចុងមានធាង និងស្លឹក ។ តាមប្រភេទពូជនិងកត្តាធាតុអាកាសក្នុងមួយឆ្នាំវាអាចបង្កើតស្លឹកថ្មីបានពី ១០ ទៅ ២០ ធាង ។ វាមាន ឫសតូច ហើយវែងចាក់ចេញពីគល់មានប្រវែងប្រមាណ១០ម៉ែត្រ ឫវែងជាងនេះ ។ ចំពោះ ដីឥដ្ឋ ឫសភាគច្រើនដុះនៅស្រទាប់ខាងលើជំរៅប្រហែល ៥០ស.មពីស្រទាប់ដីខាងលើ ប៉ុន្តែចំពោះដីខ្សាច់វាអាដុះចាក់ជ្រៅជាងនេះរហូតដល់មុខទឹកខាង ក្រោមដី ។ ផ្កាញី និងផ្កាឈ្មោលរបស់ដូងស្ថិតនៅស្រទាប់មួយ ។ នៅស្រទាប់ផ្កាមានស្មែងជាច្រើនតំរៀបជាជួរ ហើយនៅក្នុងស្មែងផ្កាមួយមានផ្កាញីមួយនៅខាងគល់ និងនៅខាងលើផ្កាញីបន្តរហូតដល់ចុងស្មែងគឺជាផ្កាឈ្មោល ។ តាមធម្មតានៅពេលវាបង្កកំណើតជាខូង គឺវាត្រូវការលំអងផ្សេងមករោយលើផ្កាញី ។ វាអាចមានផ្លែពី១០ ទៅ១៥ ផ្លែក្នុងមួយធ្លាយ ។ ផ្លែវារុំព័ទ្ធទៅដោយសំបក ឫស្រកីហើយមាន

ត្រលោករឹងគ្របដណ្តប់សាច់ផ្លែដូងពណ៌ស ។ ចន្លោះពីពេលចេញផ្ការហូតដល់ផ្លែទុំអាចមានរយៈពេលពី ១០ទៅ ១២ ខែ ។

III- អេកូឡូស៊ី ឬ បរិស្ថានវិទ្យា :

គឺជាការសិក្សាអំពីទំនាក់ទំនងជាមួយធម្មជាតិ ឬ មជ្ឈដ្ឋានតំរូវការជុំវិញរបស់រុក្ខជាតិនេះ ។

១. ធាតុអាកាស :

ការលូតលាស់របស់ដូងសមស្របមានទំនាក់ទំនងទៅនឹងអាតុអាកាសដូចតទៅ :

**ក. ទឹកភ្លៀង :**

របបទឹកភ្លៀងសមស្របសំរាប់ដូងគឺប្រមាណ១២០០ម.ម ក្នុងមួយឆ្នាំ ។ ប៉ុន្តែវាអាចដុះបានល្អដែរនៅតំបន់ដែលមានកំពស់ទឹកភ្លៀង ២០០០ទៅ ២៤០០ ម.ម ក្នុងមួយឆ្នាំ ។

**ខ. សីតុណ្ហភាព** : សីតុណ្ហភាពជាមធ្យមសំរាប់លូតលាស់ពី ២០ ទៅ ៣៨ អង្សាសេ ។

**គ. កំដៅថ្ងៃ** : កំដៅថ្ងៃវែងកាន់តែល្អប្រសើរដល់ការលូតលាស់ពី និងទិន្នផល ។

**ឃ. សំណើម** : ដូងត្រូវការសំណើមខ្ពស់រហូតដល់ពី ៨០ ទៅ ៩០ភាគរយ ។ កំរិតទាបបំផុតក្នុមួយខែយ៉ាងហោចណាស់ក៏ត្រឹម ៦០ %ដែរ ។ ការដាំដុះនៅក្បែរមាត់សមុទ្រមិនមែនជាការចាំបាច់ទេ តែជាតិអំបិលអាចជួយសំរួល ដល់ការលូតលាស់សំរាប់ដំណាំដូងបានល្អប្រសើរជាងតំបន់ដ៏ទៃទៀត ។

**២. អំពីដី** :

ដូងត្រូវការដីធូរជ្រៅនិងស្រោះទឹកល្អដូចជាដីនៅជិតដងទន្លេ ឬសមុទ្រ ។ ដីល្បាប់លាយដីឥដ្ឋមានជីជាតិ និងមាន pH ក្រោម៤,៥ ជាប្រភេទដីដ៏ប្រសើរបំផុតសំរាប់ដំណាំដូង ។

IV- បច្ចេកទេសដាំដុះ :

**១. ការជ្រើសរើសពូជ :**

ផ្លែដូងសំរាប់យកមកធ្វើពូជត្រូវជ្រើសរើសចេញពីក្នុងធ្លាយដែលមានផ្លែច្រើន និងជាប្រភេទពូជដែលមានផ្លែច្រើនសាច់ក្រាស់ ហើយជ្រើសរើសផ្លែដែលធំៗហើយទុំល្អ មុននឹងយកផ្លែដូងពូជទៅបណ្តុះយើងត្រូវយកផ្លែដូងទាំងនោះទៅទុកនៅកន្លែងមួយក្នុងម្លប់កុំអោយត្រូវភ្លៀង ហើយអោយមានខ្យល់ចេញចូលល្អគឺនៅពេលដែលយើងចាប់អង្រួនវា យើងឮស្វរសំលេងទឹកយ៉ាងច្បាស់ ។

**២. ការបណ្តុះ :**

មុននឹងដាំគេត្រូវយកផ្លែដូងទៅបណ្ដុះសិន ។

ភាគច្រើនដូងមុននិងយកទៅដាំក្នុងចំការជាទ្រង់ទ្រាយធំ

គេមិនត្រឹមតែយកទៅដាក់បណ្ដុះប៉ុណ្ណោះទេគឺបន្ទាប់ពីដាក់បណ្ដុះនៅនឹងកន្លែងមួយពី ៤ ទៅ ៥ អាទិត្យរហូតដល់ដុះពន្លកចេញបន្តិចគេត្រូវយកវាទៅរៀបក្នុងថ្នាលជារាងត្រីកោណចន្លោះពីជ្រុងមួយទៅជ្រុងមួយប្រវែង ៦០ស.ម ក្នុងរយៈពេលពី ៤ ទៅ ៥ ខែ ទើបគេគាស់យកទៅដាំនៅក្នុងរណ្ដៅដែលបានត្រៀមរួចមកហើយ ។

**វិធីសាមញ្ញមួយក្នុងការធ្វើថ្នាល និងបណ្ដុះផ្លែដូង**

យើងត្រូវជ្រើសរើសទីកន្លែងបណ្ដុះដែលនៅជិតប្រពទឹកដូចជា ក្បែរពាងទឹក. ក្បែរអណ្ដូងទឹក .ក្បែរត្រពាំង ។ ល។ ប្រកាសំខាន់បំផុត ហើយត្រូវចងចាំនោះគឺត្រូវជ្រើសរើសរកជ្រុងដែលធំជាងគេដាក់នៅលើ ។ ផ្លែដូងមានបីជ្រុងព្រោះនៅពេលយើងបកសំបកចេញយើងនឹងឃើញភ្នែកវាក៏មានបីដែរ ភ្នែកពីរខ្វាក់ ( គ្មានវន្ធ) ភ្នែកមួយមានវន្ធ ។ ផ្នែកមានវន្ធនេះហើយដែលជាកន្លែងពន្លកដុះចេញគឺចិតនៅចំជ្រុងដែលធំជាងគេនោះឯង ដូច្នេះបើយើងបណ្ដុះដោយដាក់ជ្រុងធំនៅខាងលើ នោះពន្លកនិងដុះចេញបានត្រង់ល្អហើយធ្វើអោយដូងមានកម្លាំងលូតលាស់បានល្អប្រសើរ ។

**សេចក្ដីបញ្ជាក់** :

គួរកត់សំគាល់ថាកសិករយើងភាគច្រើនពេលយកកូនដូងទៅដាំពុំបានគិតគូពីអាយុ របស់កូនដូងនោះទេ ។ ការដាំកូនដូងនៅតូចពេកឬធំពេកអាចបណ្ដាលអោយការដុះលូតលាស់របស់វាមានភាពមិនប្រក្រតី ។ កូនដូងដែលល្អគឺត្រូវមានអាយុពី ៤ទៅ ៥ខែ គិតចាប់ពីពេលវាចេញពន្លកមក ។ ដូច្នេះបើការ ដាំដូង ប្រព្រឹតទៅនៅរដូវវស្សាគឺក្នុងខែ ពិសាខគួរចាប់បណ្ដុះវាពីខែមិគសិរ ឬខែចាយតូចមកទើបបានល្អ ។

**៣_ការដាំ :**

**ក_ ការដាំជាទ្រង់ទ្រាយធំ** : នៅលើដីចំការដែលទើបរានថ្មីគេមិនត្រូវដុតដើមឈើទាំងអស់ទេ ។ គេអាចប្រមូលដើម ឬ មែកធំៗមកតំរៀបជាជួរនៅតាមចន្លោះកូនដូងដោយដាំពពាយ កសណ្ដែកគ្របពីលើ ធ្វើយ៉ាងនេះអាចបង្កជាជីជាតិសំរាប់ដូង នៅពេលដែលឈើទាំងឡាយនោះពុករលួយ ។ ក្នុងផ្ទៃដី១ ហិកតាគេអាចដាំកូនដូង :

- សំរាប់ដូងពូជធំ ពី ១៤០ ទៅ ១៤៣ ដើម ។
- ចំពោះដូងពូជតូចវិញគឺ ១៦០ ដើម ។

យើងត្រូវដាំជារាងមុំចង្ក្រានឬត្រីកោណចំងាយពីដើមមួយទៅដើមមួយ ៥ ម៉ែត្រ និងចន្លោះជួរ ៧,៨០ ម៉ែត្រ សំរាប់ពូជដើមធំ ។ ចំពោះពូជដើមតូចចំងាយពីដើមមួយទៅដើមមួយទៀត ៣ ម៉ែត្រ និងចន្លោះជួរប្រមាណ

៧,៣០ ម៉ែត្រ ។ ជាទូទៅគេនិយមយកជួរដូងតាមទិសពីជើងទៅត្បូង ។ មិនត្រូវកប់កូនដូងអោយលប់គល់ ជ្រៅពេកទេគឺត្រូវលប់ពីលើផ្លែវាត្រឹមកំពស់ ៥ ស.ម ប៉ុណ្ណោះ ។

**៣_ការដាំជាលក្ខណៈគ្រួសារ :**

ការដាំជាលក្ខណៈគ្រួសារសំដៅយកការដាំក្នុងដីភូមិដ្ឋាន ឬតាមផ្លូវសាធារណៈ។ ប្រជារាស្រ្តខ្មែរយើងមានបច្ចេកទេសដាំដុះប្លែកៗពីគ្នា ។ ប៉ុន្តែកត្តាសំខាន់គឺការជីករណ្តៅមុននឹងដាំ ។ រណ្តៅដូងត្រូវមានទំហំ 0,៩ម៣ ឬ១ម៣ ។ នៅពេលជីកត្រូវបែងចែកអាចម៍ដីជាពីរផ្នែកគឺអាចម៍ដីជំរៅកន្លះម៉ែត្រខាងលើត្រូវដាក់ទៅមួយចំហាងដោយឡែកទៀត ។ រណ្តៅនេះត្រូវជីកទុកយ៉ាងតិចបំផុតមួយខែមុននឹងដាំ ។ ក្នុងចន្លោះពេលទុកចោលនោះយើងត្រូវឧស្សាហ៍ប្រមូលសំរាម ឬ កាកសំណល់ផ្សេងៗមកចាក់ចោលក្នុងរណ្តៅនោះដើម្បីធ្វើជាជី ។ នៅពេលដាំកូនដូងយើងត្រូវលុបដីដោយយកអាចម៍ ដីផ្នែកខាងលើមុនហើយ លាយច្របល់ជាមួយជីបាតរណ្តៅបើសិនមិនគ្រប់គ្រាន់ទេទើបយកអាចម៍ដីនៅមួយចំហៀងទៀតមកលុបបន្ថែម ។ ខាងក្រោមនេះគឺជាបទពិសោធន៍មួយចំនួនរបស់កសិករដែលដាំដូងបានទទួលលទ្ធផលយ៉ាងល្អប្រសើរ :

**_បទពិសោធន៍ទី១:** រណ្តៅដែលបានដាក់ជីធម្មជាតិរួចហើយមុននឹងដាំកូនដូង គាត់រើសកូនដុំថ្មតូចៗប៉ុនកជើង យកមកដាក់បំពេញរណ្តៅនោះរួចទើបគាត់យកកូនដូងមកដាក់ពីលើហើយលុបដីតែម្តង ។

**_ បទពិសោធន៍ទី ២ :** គាត់យកកូនក្រឡូ ឬឌីទិនដាក់អំបិលអោយជិតពេញហើយចងគ្របមាត់ដោយក្រណាត់អោយជិតរួចយកទៅដាក់ក្នុងរណ្តៅនោះអោយមានកំពស់ល្មមដាំកូនដូងពីលើបានរួច ទើបលុបដី ។

**៤_ការថែរទាំ :** គេតែងតែនិយមថា ដូងដែលដាំបានល្អគេនឹងនៅទីកឃើញអស់មួយជីវិត ។ ដូងល្អអាចអោយផលក្នុងឆ្នាំទី ៤ រឺទី៥ ។ ចំនែកដើមដូងដែលដុះមិនល្អវិញអាចរហូតដល់ឆ្នាំទី ១០ ទៅ ដល់ ១១ ទើបអោយផលហើយជាផលដែលមិនជាទីពេញចិត្ត ។ ក្នុងការដាំជាចំការធំៗគេអាចជួសកូនដែលងាប់នៅដើមរដូវវស្សាក្នុងឆ្នាំបន្ទាប់មកគេអាចធ្វើត្រឹមតែ២ដងជាមធ្យមក្នុងមួយឆ្នាំ ។ ជាការល្អបន្ទាប់ពីជំរះសំអាតស្មៅ ហើយត្រូវយកចំបើងគ្របគល់ដូងដើម្បីរក្សាសំណើមបានយូរ ។ បើសិនជាយើងមានដាំពពួកឡេគាម ដូចជាពពួកសណ្តែក ឬអង្ករដីជាដើម ហើយវាដុះក្រាស់ពេកយើងក៏ត្រូវដកវាចោលខ្លះដែរ ។ ចំពោះស្លឹកដូងដែលងាប់ហើយជ្រុះមកក្រោមត្រូវរើសវាមកគរតាមចន្លោះជួរដើម្បីអោយវារលួយទៅជាជីព្រោះស្លឹកទាំងឡាយនោះពុំសូវមានគ្រោះថ្នាក់ក្នុងការបង្កើតពពួកសត្វល្អិតចង្រៃបំផ្លាញវាទេ ។

**៥_ការដាក់ជី :**

**ក_ជីសរីរាង្គ** : គេអាចដាក់ជីអាចម៍គោពី ៥០គក្រ ទៅ១០០គ,ក្រ ក្នុងមួយដើមក្នុងមួយឆ្នាំ ។ គេត្រូវដាក់ជីទាំងនេះនៅក្នុងរណ្តៅដែលនៅចន្លោះជួរ ។ គេក៏អាចប្រើជីស្រស់បានដែរដែលដាំនៅតាមចន្លោះជួរទុកដូចជាការគ្របដីផង ។

**ខ_ជីគីមី** : ជីគីមីត្រូវប្រើប្រាស់ទៅតាមអាយុកាលរបស់ដូង ធាតុអាកាស និងប្រភេទដី ។ គេមិនអាចកំណត់រូបមន្តដាក់ជីគីមីលើដំណាំដូងជាទូទៅបានទេ ។ តាមធម្មតាជីគីមីត្រូវដាក់តាមរណ្តៅជំរៅប្រហែលពី ៣០ ទៅ ៥០ស,ម ចំងាយពី គល់ពី០,៥ ទៅ ២ មែត្រដោយយោងទៅតាមអាយុកាលនៃដូង ។ ត្រូវជៀសវាងការដាក់ជីអោយប៉ះនឹងគល់ចំពោះ ដូងដែលនៅតូច ។

ខាងក្រោមនេះជាឧតហាណ៍នៃការដាក់ជីនៅទ្វីបអាហ្វ្រិកគិតជា គ,ក្រក្នុងមួយដើម :

| អាយុកាល ( ឆ្នាំ) | អាសូត (N) អាម៉ូញ៉ូមស៊ុលផាត គីឡូក្រាម | ផូស្វ័រ (P) បីកាលស៊ីកផូស្វាត គីឡូក្រាម | ប៉ូតាស្យូម (K) គីឡូក្រាម គីឡូក្រាម | ម៉ាញ៉េស្យូម (Mg) គីឡូក្រាម |
|---|---|---|---|---|
| ០ | ០,២០០ | | ០,១០០ | ០,១០០ |
| ១ | ០,៣០០ | ០,២០០ | ០,១០០ | ០,២០០ |
| ២ | ០,៥០០ | | ០,៤០០ | ០,៣០០ |
| ៣ | ១,០០០ | ០,៤០០ | ០,៥០០ | ០,៤០០ |
| ៤ | | | ០,៧០០ | ០,៥០០ |
| ៥ | | ០,៦០០ | ១,០០០ | ០,៧៥០ |
| ៦ | | | ១,៥០០ | ១,០០០ |
| ឡើងទៅ | | ០,៦០០ | ១,៥០០ | ១,០០០ |

ការដាក់ជីគីមីលើដំណាំដូងអាចអនុវត្តបានពីរដង ។ លើកទី១ គឺនៅដើមរដូវវស្សាក្នុងកំឡុង ខែចេត្រ ឬ ពិសាខលើកទីពីរនៅចុងរដូវភ្លៀង គឺក្នុងខែអស្សុជ ឬកក្តិក ។

# ដំណាំឳឡឹក (water milong)

ឳឡឹកគឺជាដំណាំមួយប្រភេទដែលគេនិយមដាំ និងបរិភោគ ។ ជាទូទៅគេច្រើនបរិភោគផ្លែដែលទុំ ប៉ុន្តែគេក៏អាចយកផ្លែខ្ចីធ្វើជាបន្លែស្លបានដែរ ។ ឳឡឹកជាប្រភេទដំណាំវល្លិ ហើយកសិករអាចដាំដំណាំនេះបានស្ទើរពេញមួយឆ្នាំ ។ ដើមឳឡឹកមានសភាពភ្ជាប់ដោយថ្នាំង ។ ថ្នាំងនីមួយៗអាចដុះចេញស្លឹក ឫស ខ្នែង ព្រម ទាំងមានផ្កាញី និងផ្កាឈ្មោល ។ ឳឡឹកដែលយើងធ្លាប់ស្គាល់មានបួនប្រភេទគឺ :

- ឳឡឹកយកសាច់
- ឳឡឹកយកគ្រាប់
- ឳឡឹកយកផ្លែខ្ចី
- ឳឡឹកព្រៃ

ប៉ុន្តែយើងសិក្សាតែអំពីឳឡឹកយកសាច់តែប៉ុណ្ណោះ ។ ដំណាំឳឡឹកស្ថិតនៅក្នុងអំបូរគ្រួសារ( គូរគូប៊ីតាសេ) ដូចដំណាំល្ពៅ ននោង ត្រសក់ និងម្រះដែរ ដូច្នេះការដាំដុះក៏ប្រហែលៗគ្នាដែរ ។

## I. តំបន់ដាំដុះដំណាំឳឡឹក

នៅប្រទេសកម្ពុជាយើង គេសង្កេតឃើញមានកសិករដាំដំណាំឳឡឹកច្រើននៅតាមតំបន់មាត់ទន្លេ ដូចជានៅតំបន់ដីល្បាប់តាមបណ្តោយទន្លេមេគង្គ និងតាមតំបន់បណ្តោយទន្លេបាសាក់ ។ ហើយគេក៏អាចដាំបាននៅតាមតំបន់ខ្ពង់រាប ឬតំបន់ភ្នំមួយចំនួនបានផងដែរ អាស្រ័យទៅតាមរដូវកាល ។

## II. រដូវកាលដាំដុះ

គេអាចដាំឳឡឹកបានពីររដូវ គឺរដូវវស្សា និងនៅរដូវប្រាំង ។ ការដាំឳឡឹកនៅរដូវប្រាំងបានសមស្របបំផុតគឺនៅចន្លោះពីខែតុលា ដល់ខែកុម្ភៈ។ ចន្លោះការដាំនៅរដូវវស្សាវិញអាចដាំបានល្អនៅចន្លោះខែ ឧសភា ដល់ខែសីហា ។ ភាគច្រើនការដាំនៅរដូវវស្សាតំបន់ខ្ពង់រាបរឺតំបន់ដីខ្ពស់ ។ ចំពោះដីតំបន់ជុំវិញមាត់ទន្លេការដាំឳឡឹកនៅរដូវវស្សាមិនបានល្អទេ ព្រោះដីមានសំណើមជោគជាំខ្លាំងពេក ឬបណ្តាលមកពីកត្តាចង្រៃមួយចំនួនទៀតដូចជាជំងឺ និងសត្វល្អិតបំផ្លាញជាដើម ។

III. រយៈពេលផ្តល់ផល

អាស្រ័យទៅតាមពូជ និងរដូវដាំដុះ ។ ជាទូទៅ ចំពោះពូជស្រាលអាចប្រមូលផលបាន រយៈពេល ៦៥ថ្ងៃក្រោយពេលដាំ ។ ពូជមធ្យមប្រមូលផលក្រោយពេលចាប់ដាំពី ៧៥ ទៅ ៨០ថ្ងៃ ។ ចំណែកប្រភេទពូជធ្ងន់អាចប្រមូលផលបានពី ៩០ ទៅ ៩៥ថ្ងៃក្រោយពេលចាប់ដាំ ។ ការដាំឪឡឹកនៅរដូវត្រជាក់អាចទទួលផលជាងការដាំនៅរដូវក្តៅ ។

IV. ពូជឪឡឹក

ក្រៅពីពូជក្នុងស្រុកដែលកសិករយើងនិយមដាំ មានពូជឪឡឹកមួយចំនួនទៀតជាពូជនាំចូលមកពីប្រទេសថៃ និងវៀតណាម ។ ពូជទាំងនោះមានច្រើនប្រភេទ និងមានឈ្មោះខុសៗគ្នាអាស្រ័យទៅតាមការផលិតរបស់ក្រុមហ៊ុនផលិតពូជដំណាំជាអ្នកដាក់ឈ្មោះឱ្យ ។

V. លំដាប់លំដោយបច្ចេកទេសដាំដុះ

## ១-ការរៀបចំដី

យើងអាចរៀបចំដីដាំឪឡឹកបានតាមច្រើនរបៀបអាស្រ័យទៅតាមប្រភេទដី ។ ចំពោះដីល្បាប់ដីល្បាយខ្សាច់ខ្មៅ រឺខ្សាច់អណ្តែង គេត្រូវធ្វើការភ្ជួរដីឱ្យបាន ២-៣ដង រឺដាំក្រោយពេលប្រមូលផលស្រូវរួច ។ ការភ្ជួរ-រាស់ដីនេះធ្វើឡើងតិច ឬក៏ច្រើនដងអាស្រ័យទៅតាមស្ថានភាពជាក់ស្តែងរបស់ដីដែលយើងនឹងត្រូវធ្វើការកាំដុះនៅលើនោះពោលគឺ ធ្វើយ៉ាងណាឱ្យដីបានម៉ត់ល្អ និងស្អាតគ្មានស្មៅចង្រៃ ។ មុននឹងភ្ជួរ-រាស់គេត្រូវពិនិត្យស្ថានភាពសំណើមរបស់ដី។ ដីដែលសើមខ្លាំងពេក ឬក៏ស្ងួតពេកយើងពុំអាចភ្ជួរ-រាស់បានល្អឡើយ ដូចនេះត្រូវ អនុវត្តន៍ដូចខាងក្រោម:

- ចំពោះដីដែលសើមពេក ត្រូវហាលដីទុកឱ្យស្រស់ល្មមមុននឹងភ្ជួរ
- ចំពោះដីស្ងួតពេក ត្រូវស្រោចទឹកឱ្យសើមល្មមមុននឹងភ្ជួរ
- ដើម្បីឱ្យដីម៉ត់ល្អ ត្រូវភ្ជួរត្រឡប់ទិសផង និងក្នុងទិសដៅខ្វែងគ្នាផង
- បន្ទាប់ពីភ្ជួរ-រាស់ និង ហាលដីឱ្យបានស្ងួតល្អរួចមក គេត្រូវធ្វើរងសំរាប់ដាំដោយកាប់រណ្តៅដែលមានចន្លោះពីគុម្ពមួយ ទៅគុម្ពមួយទៀតប្រវែង ០.៥ម និងពីជួរមួយ ទៅជួរមួយប្រវែង ២ម ។ដំណាំឪឡឹកអាចដាំបានតាមវិធី ២យ៉ាងដូចខាងក្រោម:

### ក. ការដាំគ្រាប់ផ្ទាល់

ការដាំឪឡឹកដោយគ្រាបលផ្ទាល់លើករងធ្វើឡើងនៅក្រោយពេលភ្ជួរ រាស់បានស្អាតល្អ ។ ត្រូវភ្ជួរឆ្វួតជាចង្អូរ ហើយដាក់ជីកំប៉ុស្ត ឬលាមកគោដែលពុកផុយល្អចំនួន ១គ.ក្រ លាយជាមួយជី ១៥-១៥-១៥ ចំនួន ១៥ក្រាម និងជីដេ អា ប៉េ (D.A.P) ចំនួន ៥ក្រាម ក្នុងមួយរណ្តៅ ។ ក្រោយពេលដាំរួចត្រូវគ្របចំបើង ឬគល់ជញ្ជ្រាំង ឬស្មៅងាប់លើគុម្ព របស់វា ដើម្បីរក្សាសំណើម និងជីឱ្យបានយូរ ។

### ខ. ការបណ្តុះកូនក្នុងកន្ទោង

ក្រៅពីការដាំគ្រាប់ផ្ទាល់ គេអាចបណ្តុះកូនឪឡឹកនៅក្នុងកន្ទោងដែលធ្វើអំពីស្លឹកត្នោត ឬស្លឹកចេកដោយតំរៀបកន្ទោងជាជួរដាក់នៅទីកន្លែងដែលមានពន្លឺគ្រប់គ្រាន់ ។យកដីល្បាប់មានជីជាតិឬដីដំបូកមកលាយច្របល់បញ្ចូលគ្នាជាមួយជីកំប៉ុស្ត ឬជីលាមកគោដែលស្ងួត ឱ្យបានសព្វ ( ប្រើដី ១ភាគ កំប៉ុស្ត ១ភាគ ឬដី ២ភាគ កំប៉ុស្ត ១ភាគ បើពុំមានជីកំប៉ុស្តគ្រប់គ្រាន់) ។ មុនដាក់គ្រាប់ពូជបណ្តុះក្នុងកន្ទោងត្រូវហាលថ្ងៃឱ្យបាន ១ម៉ោង បន្ទាប់មកយកគ្រាប់ពូជ ទៅខ្ទប់នឹង ក្រណាត់អំបោះ ឬស្បៃត្រាំទឹករយៈពេល ២ម៉ោង រួចយកទៅផ្អាប់រយៈពេល ៦ម៉ោងទៀត រួចយកទៅកប់ក្នុងលាមកគោ ឬលាមកក្របីស្រស់ចំនួន ២ថ្ងៃ ។ ពេលឃើញគ្រាប់ពូកដុះពន្លកទើបយកទៅដាំក្នុងកន្ទោង ដែលបានដាក់ដីល្បាយរួចជា ស្រេច ។ ដាក់គ្រាប់ពូជមួយគ្រាប់ក្នុងមួយកន្ទោងហើយរោយដីម៉ត់គ្របលើគ្រាប់ពូជបន្តិចផង ។ ត្រូវស្រោចទឹកមួយថ្ងៃ ២ដង( ព្រឹក-ល្ងាច) ពេលកូនឪឡឹកមានអាយុ១០ថ្ងៃយើងអាចយកកូនបណ្តុះនេះទៅដាំលើរងបាន ។

## ២- ការដាក់ជីបំប៉ន

ក្រោយពេលដាំបាន ១០ថ្ងៃត្រូវប្រើជីអ៊ុយរ៉េចំនួន ២០ក្រាម និងជីផូស្វាត ៣០ក្រាមលាយជាមួយទឹក ៨លីត្រ ស្រោចលើឪឡឹក ២០គុម្ព ។ រយៈពេល ៧ថ្ងៃម្តងត្រូវស្រោចជីកំប៉ុស្តចំនួនមួយកំប៉ុងទឹកដោះគោក្នុងមួយគុម្ពរួចស្រោចទឹកលាងភ្លាម ។

រយៈពេល ២០ថ្ងៃ ក្រោយពីពេលដាំ ដាក់ជី ១៥-១៥-១៥ លាយជាមួយជីដេ អា ប៉េ ចំនួន ២០ក្រាម ដាក់តាមគុម្ព ។

ការដាក់ជីបំប៉នចុងក្រោយគឺជីប៉ូតាស្យូមក្លរួ (KCl) ចំនួន ០.៥ក្រាម ទៅ ១០ក្រាម ក្នុងមួយគុម្ព ។

## ៣- ការការពារដំណាំទល់នឹងកត្តាចង្រៃ

ជាទូទៅដំណាំឪឡឹកច្រើនជួបប្រទះជាញឹកញាប់ នូវជំងឺក្រាម្សៅលើស្លឹក(Powery Mildew) ។ ជំងឺនេះ តែងតែកើតឡើងលើពពួកដំណាំគ្រួសារតែមួយដូចគ្នា គឺដំបូងមានចំណុចផ្សិតតូចៗនៅលើស្លឹកក្រោយមកផ្សិត ក៏រីករាលដាល ពេញលើផ្ទៃស្លឹក ធើឱ្យដំណាំប្រែពណ៌ក្រហម- ត្នោត ហើយខ្លោចស្លឹក ។

គេអាចប្រើថ្នាំមួយចំនួនដូចជា Bavistin, Cosan,, Captan, កំរិត ១ក្រាម លាយទឹក ១លីត្របាញ់ នៅពេលឃើញ រោគសញ្ញានេះទើបកកើត ។

- ជំងឺជាំស្លឹក ឬផ្លែ :

ជាជំងឺដែលបង្កឡើងដោយមេរោគឈ្មោះ Colletorichum sp ដែលតែងតែរាតត្បាតបំផ្លាញលើផ្ទៃស្លឹក ស្ទើរគ្រប់រុក្ខជាតិ ។ ដំបូងគេឃើញចំណុចដែលបង្កដោយមេរោគ រីកធំឡើងៗហើយប្រេះស្ងួតផ្ទៃខាងៗ ជុំវិញជំងឺ មានភាពស្ងួតពណ៌ស ។ ជំងឺនេះធ្វើឱ្យឪឡឹកបន្ថយការលូតលាស់ ក្នុងករណីកើតនៅលើដើម ស្លឹក ។ ចំពោះករណីកើតនៅលើផ្លែ នឹងធ្វើឱ្យផ្លែឪឡឹកស្ងួតសំបកហើយផតចូល និងប្រេះត្រង់កន្លែងផតនោះ ។ វិធានការកំចាត់គឺ ប្រើថ្នាំប្រភេទ Dithane M-45 (Maneb) 0,2% រឺក៏ Z-78 (Zineb) 0,2% ចំនួន ៥ ទៅ ៧ថ្ងៃម្តងពេលលេចចេញរោគសញ្ញា ។

- ជំងឺរលួយឫស និងដើម

ជាជំងឺដែលតែងតែកើតលើគ្រាប់រុក្ខជាតិជាពិសេសនៅពេលសីតុណ្ហភាពមានសំនើមខ្ពស់ និងមានពពួកមេរោគចាំបំផ្លាញគ្រាប់ ដំណាក់កាលរបស់ដំណាំ ។ វិធានការកំចាត់ គឺប្រើថ្នាំ Captan រឺ Hexocap កំរិត២០-៣០ ក្រាម ក្នុងទឹក ១៥-២០លីត្រ បាញ់មួយសប្តាហ__ម្តង ។ ត្រូវបន្ថយការស្រោចទឹក ។

- សត្វល្អិតចង្រៃ :

មានក្រុមរុយអុជផ្លែ ចៃគ្រប់ប្រភេទ មមៀច មមង់ សត្វអណ្តើកមាស ។ វិធានកាកំចាត់គឺត្រូវកំចាត ស្មៅតាមរងឱ្យអស់ ចំពោះសត្វល្អិតត្រូវចាប់ដោយដៃ ក្នុងករណីធ្ងន់ធ្ងរអាចប្រើថ្នាំគីមីដូចជា Azodrin, Diazinon, Mevinphos, Desice ជាដើម ។

## ៤- ការស្រោចស្រព

ក្រោយពេលដាំរួចស្រោចទឹកមួយថ្ងៃ ២ដង ។ នៅដំណាក់កាលឪឡឹកចេញផ្កា និងក្តិបត្រូវជីកជាកូនប្រលាយ លើរងនៅចន្លោះជួរនៃរងនិមួយៗ រួចស្រោចដោយបញ្ចូលទឹកទៅក្នុងប្រឡាយនោះដោយក្នុងមួយសប្តាហ៍ ដាក់បញ្ចូលទឹក ២ ទៅ ៣ដង គឺអាស្រ័យទៅតាមស្ថានភាពសំណើមដោយលៃយ៉ាងណាកុំឱ្យដំណាំខ្វះទឹក ។

## VI. ការប្រមូលផល

គេអាចប្រមូលផលឪឡឹកបាននៅពេលផ្លែរបស់វាទុំ គឺពេលសាច់ខាងក្នុងប្រែពណ៌សទៅជាក្រហម ផ្កាឈូក ឬ ពណ៌លឿង អាស្រ័យទៅតាមប្រភេទពូជខុសៗគ្នា ។ គេអាចសំគាល់ផ្លែឪឡឹកទុំ ឬមិនទាន់ទុំទៅតាម អាយុកាលរបស់វាដូចជា : ប្រភេទពូជស្រាលទុំក្នុងរយៈពេល ៦៥ថ្ងៃ និងប្រភេទពូជធ្ងន់ ទុំក្នុងរយៈពេល ៩០_៩៥ ថ្ងៃ ក្រោយពេលដាំ ។

ម្យ៉ាងទៀតគេអាចសំគាល់ដៃក្បែរទងផ្លែស្ងួតដល់ដើមគឺបញ្ជាក់ថា ផ្លែឪឡឹកទុំអាចប្រមូលផលបាន ។ ត្រូវ បេះផ្លែឪឡឹកទុំនៅពេលព្រឹកត្រជាក់ ហើយក្រោយពេលបេះត្រូវទុកផ្លែនៅកន្លែងត្រជាក់ដើម្បីរក្សាទុកឱ្យបានយូរ ។



